**សម្ភាសន៍ជាមួយ សារី សយ ហៅ រស់ សយ ភេទប្រុស អាយុ៦១ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ “អនុសេនាធំ”**

**ស្រុកកំណើតនៅភូមិតាអោក ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្ដាល**

**រស់នៅភូមិទួលតាសេក ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ**

**ថ្ងៃទី២៥ ខែវិច្ឆកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សុខ វណ្ណៈ**

**០១:២៥:២៤**

**៣០ទំព័រ**

វណ្ណៈ: ចឹងថ្ងៃហ្នឹងថ្ងៃទី២៥ខែ១១ឆ្នាំ២០១៣ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ។

សយៈ បាទ ។

វណ្ណៈ: ខ្ញុំមិនបានមកដល់ភូមិឃុំពូហ្នឹងគឺចង់ដឹងរឿងរ៉ាវដែលកើតឡើងកន្លងមកតាំងពីសម័យសង្គ្រាមរហូតបច្ចុប្បន្នពូណាស់?

សយៈ បាទ ។

វណ្ណៈ: ចឹងបទសំភាសខ្ញុំជាពូហ្នឹង តើខ្ញុំអាចយកទៅសរសេរទុកឲ្យក្មេងជំនាន់ក្រោយបានដឹងពូមិនថាអីទេ ពូមិនយល់ទាស់ទេ?

សយៈ បាទ ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ ពូ ពូឈ្មោះអីដែរ?

សយៈ ខ្ញុំឈ្មោះ សារី សយ ។

វណ្ណៈ: ចឹងពូមានឈ្មោះ ហៅក្រៅទេ?

សយៈ ហៅក្រៅ រស់ សយ ។

វណ្ណៈ: ចឹងពូអាយុប៉ុន្មានហើយ?

សយៈ ខ្ញុំកើតឆ្នាំ១៩៥២ ។

វណ្ណៈ: ប្រពន្ធពូឈ្មោះអីដែរ?

សយៈ ឈ្មោះ អុន ។

វណ្ណៈ: គាត់អាយុប៉ុន្មានដែរ?

សយៈ កើតឆ្នាំ១៩៥៩ ។

វណ្ណៈ: ពូមានកូនចៅប៉ុន្មាននាក់សព្វថ្ងៃ?

សយៈ	កូនមាន៧នាក់ ។

វណ្ណៈ	ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សយៈ	ស្រី១ប្រុស៦ ។

វណ្ណៈ	ចឹងពូរាល់ថ្ងៃហ្នឹងមានតួនាទីអីដែរ?

សយៈ	ខ្ញុំសមាជិកក្រុមប្រឹក្សាស្រុក ។

វណ្ណៈ	ចឹងក្រៅពីជួយធ្វើការងារស្រុកហើយនៅផ្ទះពូធ្វើស្រែចម្ការឬយ៉ាងម៉េច?

សយៈ	ធ្វើស្រែចម្ការ ។

វណ្ណៈ	ចឹងកូនពូមាន៧នាក់ហ្នឹងសព្វថ្ងៃនៅក្នុងបន្ទុកគ្រួសារឬមួយមានគ្រួសារទៅនៅកន្លែងផ្សេងៗគ្នាហើយ ។

សយៈ	ភូមិមែនទែនតែមួយទេ តែមានគ្រួសារហើយអស់បួននាក់ហើយ ។

វណ្ណៈ	ចឹងនៅសល់ក្នុងបន្ទុកបីនាក់?

សយៈ	បាទ ។

វណ្ណៈ	ចឹងឪពុកពូឈ្មោះអីដែរ?

សយៈ	ឈ្មោះ រស់ ស៊ុម ។

វណ្ណៈ	ម្តាយ?

សយៈ	ជីម ចែម ។

វណ្ណៈ	ចឹងរាល់ថ្ងៃលោកទាំងពីរនៅរស់ឬមួយស្លាប់ហើយ?

សយៈ	ស្លាប់ហើយ ។

វណ្ណៈ	បងប្អូនពូបង្កើតមានប៉ុន្មាននាក់?

សយៈ	ទាំងអស់មាន៨នាក់ តែស្លាប់អស់ហើយនៅតែខ្ញុំមួយទេ ។

វណ្ណៈ	ចឹងមានស្រីប៉ុន្មានប្រុសប៉ុន្មាន?

សយៈ	មានស្រី២ប្រុស៦ ។

វណ្ណៈ	បងទី១ឈ្មោះអីដែរ?

សយៈ	បងទី១ឈ្មោះ រស់ ហួរ ។

វណ្ណៈ	ចឹងទី២?

សយៈ	ទី២ខ្ញុំហ្នឹងឯង ។

វណ្ណៈ	ទី៣?

សយៈ	ទី៣ ឈ្មោះ ស៊ិន ។

វណ្ណៈ ទី៤?

សយៈ សៀង ។

វណ្ណៈ ទី៥?

សយៈ ឈ្មោះ ស ។

វណ្ណៈ ទី៦?

សយៈ ឈ្មោះ ខេម ។

វណ្ណៈ ទី៧?

សយៈ ទី៧ឈ្មោះ ចន ។

វណ្ណៈ ហើយពួកគាត់ទាំងអស់ហ្នឹងស្លាប់ដោយសារអីទៅ?

សយៈ មើលឈ្មោះ ហួរ ហ្នឹងសម្លាប់ជំនាន់ ប៉ុល ពត ទេ ។

វណ្ណៈ គាត់មានបានចូលធ្វើបដិវត្តទេ?

សយៈ អត់ទេ មកពី១៧មេសា ។

វណ្ណៈ ចឹងឈ្មោះ ស៊ន?

សយៈ ស៊ន ហ្នឹងស្លាប់ដោយសារជំងឺទេ តាំងពីមុននេះហ្នឹងទៀត ។

វណ្ណៈ ចុះសៀង?

សយៈ សៀង ក៏ស្លាប់ដោយសារជំងឺដែរ ស្លាប់ដោយសារជំងឺទាំងអស់ ។

វណ្ណៈ ចឹងកាលហ្នឹងចូលបដិវត្តតែពូមួយទេ?

សយៈ បាទ!តែខ្ញុំមួយទេ ។

វណ្ណៈ ចឹងស្លាប់សម័យខ្មែរក្រហមតែឈ្មោះ ហួរ មួយទេ?

សយៈ បាទ!តែ ហួរ មួយ ។

វណ្ណៈ ចឹងក្រោយពីហ្នឹងស្លាប់ក្រោយ៧៩?

សយៈ បាទ ។

វណ្ណៈ ចឹងភូមិកំណើតពូនៅណាដែរ?

សយៈ ភូមិកំណើតនៅភូមិតាអោក ឃុំជ្រាំង "ឈ្រាំង"ស្រុកពញាឮ ខេត្តកណ្ដាល ។

វណ្ណៈ ចឹងសព្វថ្ងៃពូនៅភូមិអី?

សយៈ ខ្ញុំភូមិទួលតាសេក ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

វណ្ណៈ ចឹងកាលពីតូចពូមានបានរៀនសូត្រអីដែរ?

សយៈ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ "ចាស់" ។

វណ្ណៈ	នៅសាលាណាទៅ?

សយៈ	នៅសាលាវត្តតាអោកហ្នឹង គេដាក់វត្តអន្តជុំឥឡូវហ្នឹង ។

វណ្ណៈ	ចឹងមានមូលហេតុអីបានពូឈប់រៀនត្រឹមហ្នឹង?

សយៈ	ការលំបាករបស់ខ្ញុំហ្នឹងសំខាន់ទីទាល់ក្រហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងពូឈប់រៀនមុនរដ្ឋប្រហារឬមួយឈប់រៀននៅឆ្នាំរដ្ឋប្រហារឆ្នាំ១៩៧០?

សយៈ	ឈប់មុនរដ្ឋប្រហារទៀត ។

វណ្ណៈ	ចឹងនៅពេលឆ្នាំរដ្ឋប្រហារឆ្នាំ១៩៧០ពូនៅផ្ទះជួយធ្វើស្រែចម្ការឬមួយយ៉ាងម៉េច?

សយៈ	ខ្ញុំធ្វើស្រែធម្មតា ។

វណ្ណៈ	ចឹងកាលហ្នឹងពូមិនទាន់មានគ្រួសារទេ?

សយៈ	បាទ ។

វណ្ណៈ	ចឹងនៅពេលកើតរដ្ឋប្រហារឆ្នាំ១៩៧០ហើយនៅក្នុងភូមិពូមានរឿងរ៉ាវអីកើតឡើងខ្លះនៅក្នុងពេលហ្នឹង មានពីណាមកចលនាឬមានគេមកឃោសនាយ៉ាងម៉េចដែរ?

សយៈ	កាលដែលមានរដ្ឋប្រហារហើយដូចថាមានឈ្លបឃុំណាស់ ទៅចលនាបំផុសកម្លាំងឲ្យយើងចូលតស៊ូ កាលហ្នឹងមិនមែនថាចូលខ្មែរក្រហមទេ កាលហ្នឹងថាចូលព្រៃម៉ាគីនោះ ថាចូលរំដោះសម្តេចឪចឹងទេ ។

វណ្ណៈ	ចឹងកាលហ្នឹងមានដែលបានស្តាប់តាមការប្រកាសរបស់សម្តេចឲ្យកូនចៅចូលព្រៃម៉ាគីមានឮទេនៅពេលហ្នឹង?

សយៈ	កាលហ្នឹងខ្ញុំមិនបានឮផង តែមានគេអ្នកទៅបំផុសហ្នឹង ឈ្លបឃុំ មេឃុំខាងព្រៃហ្នឹងគេទៅបំផុសចឹងទៅដល់ខែ១ ឆ្នាំ១៩៧០ខ្ញុំចាប់ចូលតែម្តង ។

វណ្ណៈ	ចឹងចូលនៅឆ្នាំរដ្ឋប្រហារភ្លាម?

សយៈ	បាទ ។

វណ្ណៈ	កាលហ្នឹងគេមានមកបង្ខំឲ្យយើងទៅឬយើងមិនចង់ទៅក៏បានដែរ?

សយៈ	កាលហ្នឹងយើងស្ម័គ្រចិត្តដែរ គេអត់មានមកចាប់បង្ខំយើងទេ ។

វណ្ណៈ	ចឹងពូចូលដំបូងចេញពីផ្ទះទៅ ពូទៅនៅកន្លែងណា?

សយៈ	ខ្ញុំចេញមកនៅគេហៅថាព្រៃបារាំង១ ម្តុំថ្នាតពងគេហៅព្រៃបារាំងអាហ្នឹង ទៅចូលនៅជាមួយគេហ្នឹងឯងធ្វើឈ្លបឃុំ ។

វណ្ណៈ	ចឹងនៅខាងខេត្តកំពង់ស្ពឺ?

សយៈ	បាទ!អាហ្នឹងនៅជាប់ខេត្តនេះដែរហ្នឹង ខេត្តកណ្តាលដែលហ្នឹងនៅចន្លោះហ្នឹង ។

វណ្ណៈ៖ ចឹងមិនឆ្ងាយពីស្រុកកំណើតប៉ុន្មានទេ?

សយៈ៖ បាទ!មិនឆ្ងាយប៉ុន្មានទេ ។

វណ្ណៈ៖ ចឹងដំបូងធ្វើជាឈ្លបទេ?

សយៈ៖ បាទ!ជាឈ្លប ។

វណ្ណៈ៖ ឈ្លបកាលហ្នឹងការពារអីខ្លះទៅ?

សយៈ៖ ឈ្លបពេលហ្នឹងតាមមេឃុំទៅចលនាក្នុងភូមិអីហ្នឹង យើងតាមការពារគេហ្នឹង ។

វណ្ណៈ៖ ចឹងកាលហ្នឹងអូសទាញប្រជាជនឲ្យយល់ពីមាគ៌ាបក្ស?

សយៈ៖ បាទ!ឲ្យយល់ពីមាគ៌ាបដិវត្តនោះ ។

វណ្ណៈ៖ ចឹងពូចូលធ្វើឈ្លបហ្នឹងបានរយៈពេលប៉ុន្មានហើយបន្តទៅខាងណាទៀត ផ្លាស់ទៅកន្លែងណាហើយចូលធ្វើអីវិញ ចូលធ្វើយោធាស្រុកឬបញ្ជូនទៅសមរភូមិមុខយ៉ាងម៉េចទៀត សូមពូជួយរៀបរាប់តាមដំណើររឿងផង?

សយៈ៖ ក្រោយពីធ្វើឈ្លបហើយឆ្នាំ១៩៧១ បានចូលទៅក្នុងទ័ពតំបន់ គេហៅថាតំបន់១៥ ហើយអ្នកដឹកនាំហ្នឹងឈ្មោះ ជ័យ អន ។

វណ្ណៈ៖ មេកងពលឬមេតំបន់?

សយៈ៖ មេតំបន់ឈ្មោះ ជ័យ អន ។

វណ្ណៈ៖ ចឹងមិនមែន ចេង អន?

សយៈ៖ ជ័យ អន វន វ៉េត ជ័យ អន ។

វណ្ណៈ៖ ចឹងពូមានស្គាល់ពីណាទៀត?

សយៈ៖ អត់ទេ ខ្ញុំស្គាល់តែមួយហ្នឹងទេដំបូង ។

វណ្ណៈ៖ ចឹងកាលនៅតំបន់១៥?

សយៈ៖ បាទ!តំបន់១៥ ។

វណ្ណៈ៖ ចឹងពូទៅទ័ពតំបន់១៥ហ្នឹង វាមានទីតាំងនៅកន្លែងណាតំបន់ហ្នឹង?

សយៈ៖ តំបន់១៥ហ្នឹងមែនទែនចាប់ពីតំបន់ភ្នំស្រួចទេ ទៅក្រោយថ្មាតពងបន្តិច គេហៅភ្នំអីទេ ហើយរហូតមកដល់ភូមិពងទឹកអីហ្នឹងគឺតំបន់១៥ ហើយហ្នឹងមកដល់វត្តអង្គព្រលឹងនេះ អាហ្នឹងតំបន់របស់គេហើយហ្នឹង យើងទៅរៀនទៅសូត្រហាត់រឹកហ្វឹនអីទៅម្តុំហ្នឹងដាក់ថាវត្តអង្គព្រលឹង ក៏បានដែរ ។

វណ្ណៈ៖ ចឹងនៅម្តុំហ្នឹងយើងធ្វើការអីឬចូលសមរភូមិឬនៅពេលហ្នឹង?

សយៈ	នៅទេ តំបន់ហ្នឹងគ្រាន់តែរឹកហ៊ីនចឹងទៅ ដល់នេះទៅយើងស្នាក់វាយឈ្លបចឹងទៅណាស់ នៅមុំវ៉ាត្រពាំងត្នោត វ៉ាបាតដឹង ភ្នំបាសិទ្ធ យើងស្នាក់វាយឈ្លប ។

វណ្ណៈ	ចឹងកាលហ្នឹងវាយជាឈ្លបទេ?

សយៈ	បាទ!វាយជាឈ្លប ។

វណ្ណៈ	កាលហ្នឹងវាយជាមួយទាហាន លន់ នល់?

សយៈ	បាទៗ!ជាមួយទាហាន លន់ នល់ ។

វណ្ណៈ	នៅមុំណាខ្លះ?

សយៈ	នៅមុំវ៉ាត្រពាំងត្នោត ។

វណ្ណៈ	នៅខាងខេត្តកំពង់ស្ពឺ?

សយៈ	បាទ!ខេត្តកំពង់ស្ពឺ វ៉ាបាតដឹង មុំភ្នំបាសិទ្ធ តំបន់ភ្នំបាសិទ្ធ អាហ្នឹងវាចន្លោះខេត្តកំពង់ស្ពឺ ចន្លោះខេត្តកណ្តាល អាផ្លូវលេខ២៦ហ្នឹងនោះ ។

វណ្ណៈ	ចឹងកាលហ្នឹងមានសហការណ៍ជាមួយវៀតណាមទេ មានចូលវាយជាមួយវៀតណាមទេ?

សយៈ	ខ្ញុំមិនដែលប៉ះទេ ។

វណ្ណៈ	ចឹងពូនៅខាងកងទ័ពរំដោះហ្នឹងវាយជាមួយ លន់ នល់?

សយៈ	បាទ ។

វណ្ណៈ	ចឹងដល់ឆ្នាំ១៩៧២-៧៣ វាយសំដៅមកភ្នំពេញហ្នឹង ពូវាយតាមច្រកណា?

សយៈ	នៅឆ្នាំ១៩៧៣ ខ្ញុំបានចូលកងទ័ពខាងភូមិភាគពិសេស ។

វណ្ណៈ	ចឹងផ្លាស់ចេញពីតំបន់វិញ?

សយៈ	បាទ!ផ្លាស់ចេញពីតំបន់បានគេបញ្ជូលទៅភូមិភាគពិសេស ខ្ញុំនៅក្នុងអគ្គភាពវរសេនាតូច លេខ២១៤ ។

វណ្ណៈ	ពីណាគេជាប្រធានវរៈពេលហ្នឹង?

សយៈ	ដឹកនាំដោយលោក អ៊ី អង់អាច ចឹងតែម្តង ។

វណ្ណៈ	ចឹងគាត់ប្រធានវរសេនាតូច?

សយៈ	បាទ!ហើយសមរភូមិប្រយុទ្ធនៅខាងលិចភ្នំពេញ មុំអង្គស្នួល មុំបែកចាន កប់ស្រូវហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងនៅក្នុងកងពលណាដែរ?

សយៈ	កាលហ្នឹងមិនទាន់កើតកងពលទេ ។

វណ្ណៈ	ចឹងឆ្នាំ១៩៧៣ហើយមិនទាន់មានកងពលទៀត?

សយៈ	គេរៀបចំជាកងពលទ័ពពិសេសគេបង្កើតជាវរសេនាតូច គឺប្រចាំនៅភូមិភាគពិសេសដល់ឆ្នាំ ១៩៧៤ អាហ្នឹងកើតជាអង្គភាពកងពលហើយ ។

វណ្ណៈ	កងពលលេខប៉ុន្មាន?

សយៈ	កងពលលេខ៨០ ១ហ្នឹងតែម្តង ។

វណ្ណៈ	ពីណាជាប្រធានកងពល?

សយៈ	ឈ្មោះ សួរ សារឿន ។

វណ្ណៈ	សួរ សារឿន ហៅ ០៥?

សយៈ	បាទ!ហើយសមរភូមិចាប់ពីកប់ស្រូវរហូតមកដល់ពោធិចិនតុងនេះ ហ្នឹងសមរភូមិក្តៅគគុកហើយ ។

វណ្ណៈ	ចឹងសមរភូមិពូវាយចូលទីក្រុងភ្នំពេញហ្នឹង គឺវាយចូលតាមផ្លូវពោធិចិនតុង?

សយៈ	បាទ!តាមពោធិចិនតុង ។

វណ្ណៈ	ចឹងកាលហ្នឹងអនុតាសារឿន ពីណាគេ?

សយៈ	អនុតាសារឿន មានពីណាទេភ្លេចអស់បាត់ហើយ ។

វណ្ណៈ	ចឹងពេលវាយចូលដល់ទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ពេលហ្នឹងពូមានបានចូលទេ?

សយៈ	ខ្ញុំចូលទៅនៅហ្នឹងបានប្រហែលជា៥ទៅ៦ខែដែរ ។

វណ្ណៈ	កាលហ្នឹងពូបានចូលដល់ភ្នំពេញថ្ងៃទីប៉ុន្មាន?

សយៈ	ខ្ញុំថ្ងៃទី១៧មេសាហ្នឹងគឺចូលតែម្តង ព្រឹកឡើងដល់តែម្តង ។

វណ្ណៈ	ចឹងព្រឹកម៉ោងប៉ុន្មាន?

សយៈ	ប្រហែលជាម៉ោង៨-៩ហ្នឹងឯងប្រហែលជា៩ហ្នឹងទៅដល់ស្តាតតែម្តង ។

វណ្ណៈ	ចឹងពេលចូលដល់ទីក្រុងភ្នំពេញយើងប្រាប់ឲ្យប្រជាជនចេញ យើងអត់មានប្រើអាវុធបាញ់ទេ?

សយៈ	អត់ទេ ។

វណ្ណៈ	ចឹងគាន់តែប្រាប់ឲ្យប្រជាជនចេញពីក្រុង?

សយៈ	បាទ!ប្រាប់ឲ្យប្រជាជនចេញពីក្រុង ។

វណ្ណៈ	អាហ្នឹងបញ្ជាមកពីខាងណាវិញ?

សយៈ	បញ្ជាពីបក្សតែម្តង ។

វណ្ណៈ	ចឹងកាលហ្នឹងប្រជាជនចេញរយៈពេលប៉ុន្មានថ្ងៃអស់?

សយៈ	រយៈចេញហ្នឹងដូចជានៅរតេករតាកដែលកាលហ្នឹង ចេញបីថ្ងៃហ្នឹងក៏មិនទាន់ចប់ដែរ ។

វណ្ណៈ ចឹងប្រហែលជាមួយអាទិត្យ?

សយៈ បាទ!ប្រហែលមួយអាទិត្យអីហ្នឹង ។

វណ្ណៈ ចឹងកាលចូលដល់ទីក្រុងភ្នំពេញដំបូង ពូមានដឹងថា មានប៉ុន្មានកងពលចូលហ្នឹង?

សយៈ មើលខាងខត្តរក៏ចូល ដូចជាមានច្រើនដែរ ព្រោះគ្រប់ច្រក មានច្រើនកងពល មែនទែន ទៅចេញមកខ្ទប់បណ្តោយ ពីច្រកណាក៏ចូលខាងក្រោមក៏ចូលខាងលើក៏ចូលពីខាងលិចពីខាងជើង ពីខាងត្បូង រួមគ្នាតែម្តងចាប់ដៃគ្នានៅស្អាត ។

វណ្ណៈ ចឹងពេលដែលប្រជាជនចេញអស់តើគេរៀបចំកម្លាំងយោធាគ្រប់កងពលហ្នឹង គេបែងចែកយ៉ាងម៉េចវិញទៅ ពេលប្រជាជនចេញអស់?

សយៈ ពេលដែលគេរៀបចំចេញហើយហ្នឹង ខ្ញុំកងពលពួកខ្ញុំនេះគេផ្លាស់មកខាងខេត្តរតនគិរី ។

វណ្ណៈ កងពល៨០១ហ្នឹង?

សយៈ បាទ!កងពល៨០១មកខាងខេត្តរតនគិរី ។

វណ្ណៈ ចឹងក្នុងឆ្នាំ១៩៧៥ដែរ?

សយៈ អេ!មើល មិនមែនក្នុងឆ្នាំ៧៥ទេ នៅក្នុងឆ្នាំ៧៦ហើយតាមមើល វាយូរណាស់ដែលពិបាកចាំណាស់ តែក្នុងឆ្នាំ១៩៧៥ហ្នឹងមិនទាន់ចេញមកទេ ខ្ញុំផ្លាស់មកខេត្តរតនគិរី ។

វណ្ណៈ ចឹងទៅមួយកងពលហ្នឹងមានគ្នាប្រហែលជាប៉ុន្មាននាក់?

សយៈ គ្នាបើសរុបទៅមានខាងសេដ្ឋកិច្ច មានកងនារីនោះ ហើយមានកងពិសេស មានកងកាំភ្លើងធំ បែបខ្ទង់៥០០០នាក់ហ្នឹង ។

វណ្ណៈ ចឹងមានច្រើន?

សយៈ មានច្រើនណាស់ ។

វណ្ណៈ មានស្រីដែរ?

សយៈ ស្រីមានអគ្គភាព៨០៤គេហ្នឹងមានមួយវរសេនាតូច ។

វណ្ណៈ តែនៅក្នុងកងពល៨០១ដែរ?

សយៈ នៅក្នុងកងពល៨០១ ។

វណ្ណៈ ចឹងគ្នា៥០០០នាក់ហ្នឹងមានស្រីមានប្រុស?

សយៈ ហ្នឹងហើយមានស្រីមានប្រុស ។

វណ្ណៈ ចឹងស្រីមានតិច?

សយៈ បាទ!ស្រីមានតែមួយវរសេនាតូចទេ មានប្រហែលជា៤០០ជាងហ្នឹង ។

វណ្ណៈ ចឹងខាងស្រីមានលេខអគ្គភាពផ្សេងទៀត?

សយៈ	មើលកាលហ្នឹងមាន៨០៣ មាន៨០៤ ហ្នឹងគេដាក់ថា០៤នោះគេដាក់ថា ៨០៤ ។

វណ្ណៈ	ចឹងអាហ្នឹងគេបំបែកជាអង្គភាពទេ?

សយៈ	គេបំបែកជាអង្គភាពទេ នៅក្រោមការដឹកនាំរបស់កងពល៨០១ហ្នឹង ។

វណ្ណៈ	ចឹងពេលហ្នឹងប្រធានកងពល៨០១ហ្នឹងពីណាគេ?

សយៈ	មានតែ សូរ សារឿន ហ្នឹងហើយ ។

វណ្ណៈ	ចឹងដដែល?

សយៈ	បាទ!ដដែល ហើយក្រោយមកមាន អ៊ុង វ៉ែន យើងហ្នឹងគាត់នៅក្នុង៨០១ដែរ ។

វណ្ណៈ	ចឹង អ៊ុង វ៉ែន ហ្នឹងអនុ?

សយៈ	បាទ!គាត់អនុ ។

វណ្ណៈ	គាត់នៅរស់ទេឥឡូវ?

សយៈ	គាត់នៅតើ គាត់នៅក្នុងក្រុមប្រឹក្សាដែរ ។

វណ្ណៈ	ចឹងបន្ទាប់ពីឈ្មោះ អ៊ុង វ៉ែន មានពីណាទៀត?

សយៈ	មានឈ្មោះ ស៊ួ សុន ទេ ។

វណ្ណៈ	ចឹងគេថាមានឈ្មោះ ស៊ុង អីនោះ?

សយៈ	ស៊ុង អត់មានស្គាល់ទេ ។

វណ្ណៈ	ស៊ុង ហ្នឹងថាគេចាប់គាត់បាត់ទៅ មានឈ្មោះ ស៊ុង នៅក្នុងកងពលហ្នឹង?

សយៈ	តែខ្ញុំស្គាល់តែ សុន ទេ តែមិនដឹងថាស៊ួ សុនទេ ។

វណ្ណៈ	ចឹងគាត់ជាអនុកងពលដែរ?

សយៈ	បាទ ។

វណ្ណៈ	ចឹង សុន ហ្នឹងគេចាប់ខ្លួនទេ?

សយៈ	អត់ទេ ។

វណ្ណៈ	ចឹងគាត់នៅទេ?

សយៈ	បាទ! ពេលឆ្នាំ១៩៧៩ ពេលរត់បែកបាក់គ្នាមិនដឹងជាទៅខាងណា ។

វណ្ណៈ	ចឹងកាលទៅដល់ខេត្តរតនគីរីហ្នឹងនៅក្នុងស្រុកអីទៅ?

សយៈ	នៅក្នុងស្រុកវើនសៃ ទីតាំងនៅក្នុងស្រុកវើនសៃ មាត់ទន្លេសេសាន ។

វណ្ណៈ	ចឹងកាលដែលពូបានទៅដល់ភ្នំហ្នឹង យើងត្រូវធ្វើយ៉ាងម៉េចខ្លះត្រូវកសាងរចនាសម្ព័ន្ធឬកន្លែងទីតាំងយ៉ាងម៉េចខ្លះ ហើយកាលហ្នឹងមានអ្នកឈឺចាញ់ស្លាប់អីទេ ពេលទៅដល់ដំបូងថ្មីៗហ្នឹង?

សយៈ ខ្លាំងមែនទែន រឿងជីងី ខ្ញុំរៀបរាប់បញ្ហាហ្នឹងគឺដល់ដំបូងចែកជាពីរទី១ទៅការពារព្រំដែន ទី២នៅបង្កបង្កើនផល ។

វណ្ណៈ ចឹងទី២ជាយោធាដែលតែនៅធ្វើស្រែ?

សយៈ បាទ ។

វណ្ណៈ ចឹងមានតែពីរមុខសញ្ញាហ្នឹងទេ?

សយៈ បាទ ។

វណ្ណៈ ចឹងនៅក្នុងហ្នឹងមានអង្គភាពពេទ្យដែរ?

សយៈ មានអាហ្នឹងគេហៅអង្គភាព៨០៥ហើយមានអង្គភាពកង៨០៦កងដឹកជញ្ជូនទៀត ។

វណ្ណៈ ចឹងអង្គភាពពេទ្យ៨០៥?

សយៈ បាទ!៨០៥ ។

វណ្ណៈ ចឹងអង្គភាពដឹកជញ្ជូន?

សយៈ អង្គភាពដឹកជញ្ជូន៨០៦ ។

វណ្ណៈ ចឹងអាហ្នឹងមិនមែនកងពលទេ?

សយៈ មិនមែនកងពលទេ នៅក្នុងកងពល៨០១ ។

វណ្ណៈ ចឹងអង្គភាពពេទ្យហ្នឹងមានពីណាប្រធានពូមានដឹងទេ?

សយៈ គេហៅ វ៉ាយ សារឹម តែគាត់ស្លាប់បាត់ហើយ ។

វណ្ណៈ ចឹងខាងដឹកជញ្ជូន?

សយៈ ខាងដឹកជញ្ជូនគេហៅឈ្មោះ ស៊្រី ម៉ុន ទេ តែស្លាប់ហើយ ។

វណ្ណៈ ចឹងកាលពូនៅដល់ស្រុករឹនសៃហ្នឹងពូនៅខាងធ្វើស្រែឬនៅជួរមុខអង្គភាពការពារ?

សយៈ ខ្ញុំនៅអង្គភាព៨០៣ គឺខាងកាំភ្លើងធំ កងកាំភ្លើងធំមួយវរសេនាតូច ។

វណ្ណៈ ចឹងកងកាំភ្លើងធំការពារខាងមុខ?

សយៈ អត់ទេ នៅខាងក្រោយ លុះត្រាមានសភាពការណ៍ខាងមុខបានយើងធ្វើដំណើរទៅ ដោយឡែកបើមិនមានសភាពការណ៍អី គឺនៅបង្កបង្កើនផល រួមជាមួយ៨០៥និង៨០៦និង៨០៤ ធ្វើស្រែចម្ការនៅខាងក្រោយ ។

វណ្ណៈ ចឹងពេលតែកំពង់ធ្វើស្រែធ្វើចម្ការដែលអង្គការចាត់តាំងមកហ្នឹង តើនៅក្នុងពេលហ្នឹងមានការផ្លាស់ប្តូរមនុស្សឬមានការចាប់ចងមនុស្សមានទេ នៅពេលហ្នឹង?

សយៈ ខ្ញុំត្រង់ហ្នឹងភ្លាប់មិនបាន ព្រោះចេះកាលហ្នឹងយើងខំធ្វើចឹងទៅ ការបាត់បង់មនុស្សវាមិនឃើញនៅក្នុងហ្នឹង ឃើញតែមករួមគ្នាធ្វើស្រែធ្វើចម្ការហ្នឹងទៅ ឯការចាប់អ្នកនេះចាប់អ្នក

នោះអី ឧទាហរណ៍អគ្គភាពមានបីបុមានបួនវរសេនាធំចឹង មាន៨១-៨២-៨៣ អាហ្នឹង គេនៅព្រំដែនតាមវរសេនាធំផ្សេងៗ ដូចនេះការបាត់បង់យើងមិនបានដឹង តែចំពោះជុំវិញ មន្ទីរមាន៨០៣-៨០៤-៨០៥-៨០៦ហ្នឹង ដូចជាមិនឃើញមានបាតុភាពទេ ។

វណ្ណៈ: ចឹងកាលហ្នឹងគេឲ្យឋានៈពូត្រឹមណាដែរ?

សយៈ: ខ្ញុំអនុសេនាធំ ។

វណ្ណៈ: អនុសេនាធំគ្រប់គ្រងមនុស្សប៉ុន្មាននាក់ដែរ?

សយៈ: មាន១២០នាក់ ។

វណ្ណៈ: ចឹងការហូបចុករបស់កងទ័ពនៅពេលហ្នឹងយ៉ាងម៉េចដែរ?

សយៈ: កាលហ្នឹងមានការលំបាកណាស់បើនិយាយទៅ មិនថាទ័ពមិនថាមូលដ្ឋានអីទេ តាមមើល មួយចានដូចតែគ្នាហ្នឹង ។

វណ្ណៈ: ចឹងបើនិយាយរឿងហូបចុកវិញខាងកងទ័ពបានគ្រាន់បើជាងខាងសហករណ៍ដែរ?

សយៈ: បាទ!តែសហករណ៍មួយនៅក្បែរខ្ញុំហ្នឹង ខ្វាំងណាស់ជនជាតិទាំងអស់ហ្នឹងហូបមួយវែ្ឆតតែ ម្តង ។

វណ្ណៈ: បាទ!ខ្ញុំជឿថាមាន នៅក្នុងសម័យខ្មែរក្រហមថ្មីត្បិតថា មានតំបន់ខ្លះអត់ឃ្លានមែនហើយ យកទៅសម្លាប់មែន តែមានតំបន់ខ្លះសហករណ៍មានការហូបចុកគ្រប់គ្រាន់ដែរ?

សយៈ: បាទ!ខ្ញុំឃើញសហករណ៍ហ្នឹងហៀហូរតែម្តង ។

វណ្ណៈ: ចឹងកាលហ្នឹងក្រៅពីតាសារឿន គ្រប់គ្រងពូហ្នឹង ហើយមានថ្នាក់ដឹកនាំណាចុះទៅសួរសុខ ទុក្ខយ៉ាងណាដែលទេ កាលជំនាន់បីឆ្នាំហ្នឹង ជំនាន់ពីឆ្នាំ១៩៧៥ដល់៧៩ហ្នឹង?

សយៈ: ជំនាន់ហ្នឹងបើតាមដឹងទៅ ពេលគាត់ដឹកនាំកងពលហ្នឹងហើយ គាត់បានទទួលនេះទៀត ក្រោយពីចាប់លោកណានៅហ្នឹងមកគាត់ទទួលភូមិភាគនៅហ្នឹងទាំងអស់តែម្តង ។

វណ្ណៈ: ចាប់ពីណាគេ?

សយៈ: ចាប់ឈ្មោះ យ៉ា ចឹង លោក យ៉ា ។

វណ្ណៈ: យ៉ា ហ្នឹងជាគណៈតំបន់?

សយៈ: គណៈភូមិភាគ ក្រោយពីចាប់ទៅគាត់គ្រប់គ្រងទាំងអស់តែម្តង លោក សូរ សារឿន ហ្នឹង កាលហ្នឹង ។

វណ្ណៈ: ចឹងកាលហ្នឹងលោក សូរ សារឿន គាត់គ្រប់គ្រងប្រជាជនគ្រប់គ្រងទាំងទ័ព?

សយៈ: បាទ!គ្រប់គ្រងទាំងប្រជាជនទាំងទ័ព តែបានរយៈពេលខ្លីទេ ។

វណ្ណៈ: ចឹងគណៈតំបន់នៅពេលហ្នឹងពូមានស្គាល់ទេ?

សយៈ ខ្ញុំមិនស្គាល់ទេ ។

វណ្ណៈ ចឹងស្គាល់តែឈ្មោះ យ៉ា គេចាប់ហ្នឹងទេ?

សយៈ បាទ!ស្គាល់តែ យ៉ា ទេ ។

វណ្ណៈ ចឹងរយៈពេលប៉ុន្មានឆ្នាំពូនៅវីនសៃហ្នឹង ពូមានបានមកលេងស្រុកកំណើតទេ?

សយៈ អត់ទេ រឿងហ្នឹងចប់បណ្ដោយ មិនបានមកលេងទេ ។

វណ្ណៈ ចឹងកាលយើងធ្វើដំណើរចេញពីភ្នំពេញទៅ កាលហ្នឹងយើងជិះអីទៅ កាលជំនាន់ហ្នឹង?

សយៈ កាលហ្នឹងយើងជិះកាណូត ។

វណ្ណៈ ជិះកាណូតទៅឈប់ត្រឹមណា?

សយៈ ឈប់ត្រឹមក្រចេះ ។

វណ្ណៈ ចឹងឈប់នៅក្រចេះហ្នឹងប៉ុន្មានថ្ងៃទៅ?

សយៈ នៅក្រចេះហ្នឹងបានរយៈពេលតែបីថ្ងៃទេ ។

វណ្ណៈ ចឹងបន្តទៅជិះអីទៅទៀត?

សយៈ កាលខ្ញុំជិះឡាន ។

វណ្ណៈ ចឹងជិះឡានទៅដល់វីនសៃតែម្ដង?

សយៈ បាទ!ឡានទៅដល់បាលុង វីនសៃ ។

វណ្ណៈ ចឹងពេលទៅដល់ហ្នឹងបានមានបែងចែកកម្លាំងខ្លះទៅការពារខាងមុខខ្លះនៅធ្វើស្រែចឹង?

សយៈ បាទ ។

វណ្ណៈ ចឹងការពារព្រំដែនកាលហ្នឹងមានប៉ះជាមួយឡាវជាមួយយួនអីទេ កាលហ្នឹងប៉ះវាយគ្នាដែរទេ?

សយៈ មានប៉ះដែលកាលនៅកន្ទុយនាគ ។

វណ្ណៈ នៅកន្ទុយនាគហ្នឹងប៉ះគ្នានៅឆ្នាំណា?

សយៈ កាលនៅកន្ទុយនាគហ្នឹងប៉ះគ្នាញឹកញាប់ដែរ តែគ្រាន់គេតាមព្រំដែនទេណាខ្ញុំនៅខាងក្រោយនេះទេ ។

វណ្ណៈ ចឹងកាលហ្នឹងមានប៉ះជាមួយឡាវទេ?

សយៈ អត់មានទេ ឡាវខ្ញុំគ្នាប់មិនបានទេ តែកន្ទុយនាគដុកគឺហ្នឹងខសង្រ្គាប់ប៉ះ ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៧៩ ពេលវៀតណាមវាយចូលតែឆ្នាំ៧៨អីហ្នឹងយើងមានវាយជាមួយវៀតណាមទេ?

សយៈ កាលហ្នឹងវាយ ។

វណ្ណៈ	ចឹងនៅពេលដែលកងទ័ពវៀតណាមវាយចូលដល់ប្រទេសកម្ពុជាចូលដល់ភ្នំពេញអីហ្នឹង ចឹងកងពល៨០១របស់ពូហ្នឹងទៅខាងណាវិញទៅ?

សយៈ	នៅឆ្នាំ១៩៧៩ដែលវៀតណាមចូលទៅ ពួកខាងខ្ញុំចូលទៅព្រៃ នៅតាមតំបន់ភ្នំ រួមដល់ឆ្នាំ១៩៨០ បាននាំគ្នាឡើងមកភ្នំវិញ ។

វណ្ណៈ	ចឹងដល់ឆ្នាំ១៩៨០ឡើងដល់ភ្នំដងរែក?

សយៈ	បាទ!ហើយច្រកហ្នឹងគេហៅថា១០០១ ។

វណ្ណៈ	ចឹងដំបូងនៅដល់៨០៨សិនឬទៅដល់១០០១តែម្តង?

សយៈ	អត់ទេ ពួក១០០១ខ្ញុំ តំបន់ខ្ញុំគឺ១០០១តែម្តង ។

វណ្ណៈ	ចឹងពីណាដឹកនាំនៅ១០០១?

សយៈ	១០០១ហ្នឹងនៅប្រចាំហ្នឹងលោក សុន សេន ។

វណ្ណៈ	ចឹងកាលនៅ១០០១ធ្វើអីខ្លះកាលហ្នឹង?

សយៈ	ធ្វើទ័ព ។

វណ្ណៈ	កាលហ្នឹងបានជំនួយមកពីប្រទេសណា?

សយៈ	មានតែចិនដដែលហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹង សុន សេន នៅខាងឃ្លាំងឬនៅខាងបញ្ជាទ័ព?

សយៈ	គាត់បញ្ជាទ័ព តែតំបន់ហ្នឹងគឺគាត់គ្រប់គ្រងនៅ១០០១ ។

វណ្ណៈ	ចឹងនៅ១០០១ហ្នឹងគឺអង្គភាពកងពល៨០១ហ្នឹង ឬកងពល៨០១ហ្នឹងមានបែងចែកទៅនៅកន្លែងផ្សេងទៀត?

សយៈ	៨០១ហ្នឹងមាន៤១៧មិញហ្នឹងនៅក្នុង១០០១ដែរ ៨០១ក៏នៅ១០០១ដែរ គ្រាន់ហ្នឹងមានតែពីរអង្គភាពហ្នឹងទេ ។

វណ្ណៈ	ចឹងមាន៨០១និង៤១៧?

សយៈ	បាទ ។

វណ្ណៈ	នៅ១០០១ហ្នឹង?

សយៈ	បាទ ។

វណ្ណៈ	ចឹងលោក សុន សេន គ្រប់គ្រង១០០១វិញ លែងតាសារឿន?

សយៈ	បាទ!សុន សេន ហ្នឹងលើតាសារឿន ទៀត ។

វណ្ណៈ	ចឹងតាសារឿននៅហ្នឹងដែរ?

សយៈ	បាទ!តាសារឿន នៅហ្នឹងដែរ តាកែ ពក នៅហ្នឹងដែរ ។

វណ្ណៈ៖ ចឹង៨១៧ហ្នឹង?

សយៈ ៨១៧ហ្នឹង កែ ពក នៅហ្នឹងដែរ ។

វណ្ណៈ៖ តែនៅក្រោម សុន សេន ទាំងអស់?

សយៈ បាទ ។

វណ្ណៈ៖ ចឹងពេលហ្នឹងនៅ១០០១ ដល់ពេលយើងធ្វើការវាយបកមកខាងរដ្ឋាភិបាលនិងវៀតណាម កាលហ្នឹងរដ្ឋាភិបាលខាងលោក ហេង សំរិន ដែលសហការណ៍ជាមួយខាងវៀតណាមហ្នឹង យើងចុះមកខាងច្រកណាខ្លះដែរ?

សយៈ ចុះមកខាងព្រះវិហារ កំពង់ធំ កំពង់ចាម នៅស្រុកព្រៃឈរ ហើយក្នុង៨០១ហ្នឹងចុះមកដល់ព្រៃនៅខាងព្រែកក្ដាមហ្នឹង៨០១ដែរ ។

វណ្ណៈ៖ ចឹងកាលចុះមកមានគ្នាច្រើនទេ?

សយៈ ចុះទៅតាមរយៈមូលដ្ឋានខាងក្រោយ ឧទាហរណ៍ព្រះវិហារ៣០០ខាងកំពង់ធំ២០០តែមកកំពង់ចាម១០០ដាង ទៅខាងនោះតែមួយក្រុមទេ ចល័តតាមសមរភូមិដែលអាចនៅកម្លាំងច្រើនបាន សមរភូមិដែលអាចនៅកម្លាំងតិចបាន អាហ្នឹងតាមជាក់ស្ដែង ។

វណ្ណៈ៖ ចឹងដូចពូឈរជើងនៅខាងណា?

សយៈ ខ្ញុំមែនទែនខ្ញុំចល័តមកខាងព្រះវិហារក៏ខ្ញុំចុះ កំពង់ធំក៏ខ្ញុំចុះ កំពង់ចាមក៏ខ្ញុំចុះ ខ្ញុំឈរនៅហ្នឹងកាលហ្នឹង ។

វណ្ណៈ៖ ចឹងពូចល័តគ្រប់កន្លែង?

សយៈ បាទ ។

វណ្ណៈ៖ ចឹងនៅពេលយកគ្រាប់យកកាំភ្លើងឬចំណីអាហារអីយ៉ាងម៉េចទៅ ព្រោះអ្នកខ្លះទៅនៅជិតភ្នំពេញហើយហ្នឹង ព្រែកក្ដាម កំពង់ធំអីចឹង យើងយកពីលើភ្នំនេះទៅឬមានការដោះស្រាយនៅខាងក្នុងហ្នឹងតែម្ដង?

សយៈ ចំពោះគ្រាប់យើងដញ្ជូនពីលើភ្នំ ឯស្បៀងអាហារដោះស្រាយប្រជាពលរដ្ឋនៅខាងក្រោមហ្នឹងតែម្ដង មានការទិញ ការដូរដោះ ជាសារ៉ុង ជាក្រណាត់អីចឹង ។

វណ្ណៈ៖ ចឹងមានខាងរដ្ឋអំណាចចាប់បានទេ បើយើងធ្វើការទាក់ទងដោះដូរជាមួយប្រជាជនចឹង មានចាប់បានដែរ?

សយៈ កាលហ្នឹងមានចាប់បានប្រជាជនហ្នឹងឯង យើងនេះវាមិនងាយចាប់ទេ ។

វណ្ណៈ៖ ចឹងចាប់បានតែប្រជាជនទេ?

សយៈ បាទ ។

វណ្ណៈ	ចឹងបើគេស៊ើបដឹងប្រជាជនអាចមានបញ្ហាដល់ជាប់គុកអីទេ?

សយៈ	បាទ! យើងមុនហ្នឹងនេះ បើមានទាហានយួនទាហានខ្មែរចេញមកចឹង យើងដឹងបាត់ហើយ ប្រជាជនគាត់ប្រាប់មកហើយ អក! នៅមិនបានទេ ត្រង់នេះៗគេច ។

វណ្ណៈ	ចឹងប្រជាជនក៏ជួយប្រាប់មកខាងខ្មែរក្រហមអីចឹងដែរ?

សយៈ	បាទ ។

វណ្ណៈ	ចឹងកាលដែលវាយជាមួយវៀតណាមហ្នឹងមើលទៅសកម្មភាពហ្នឹងខ្លាំងខ្លាដែរឬមួយយ៉ាងម៉េច កាលសង្គ្រាមហ្នឹង?

សយៈ	ខ្លាំងដែរ ទៅតាមកល្បិចកលវិធីរបស់យើងដែលវាយ មកធំមកយើងវាយតូចទៅ បើមកតូចទៅយើងវាយធំទៅ សុទ្ធតែមានយុទ្ធសាស្ត្រវាយ ល្បិចសង្គ្រាមវាយជាមួយវៀតណាមហ្នឹង យើងលេងយកទាំងផ្ទាំងក៏អត់បានដែរ ។

វណ្ណៈ	ចឹងពូគិតថាសង្គ្រាមសម័យក្រោយឆ្នាំ១៩៧៩ហ្នឹង បានធ្វើឲ្យជីវិតមនុស្សស្លាប់ច្រើនទេ?

សយៈ	ស្លាប់យួនក៏ច្រើន ប្រជាពលរដ្ឋយើងក៏ច្រើនដែរ ។

វណ្ណៈ	ចឹងស្លាប់ច្រើន?

សយៈ	បាទ ។

វណ្ណៈ	ចឹងស្លាប់យួនក៏ច្រើនដែរ?

សយៈ	បាទ ។

វណ្ណៈ	ចឹងពូមានដឹងថា ពេលណាកងទ័ពវៀតណាមគេឲ្យដកចេញពីប្រទេសកម្ពុជាអស់ កាលហ្នឹងពូមានដឹងទេ?

សយៈ	ដូចជាឆ្នាំ១៩៩០ ខ្ញុំគ្រាន់ពូតែថាទេ អាហ្នឹងឆ្នាំ១៩៨៨ខ្ញុំវាពិការហើយដូចនេះខ្ញុំនៅខាងក្រោយទេ ។

វណ្ណៈ	ឆ្នាំ៩០ឬឆ្នាំណា?

សយៈ	ឆ្នាំ១៩៨៨ ខ្ញុំពិការហើយ ឆ្នាំ១៩៨៨ ។

វណ្ណៈ	កាលហ្នឹងជាន់មីន?

សយៈ	បាទ! ជាន់មីននៅអូរអង្រ្រែយើងនេះ អូរអង្រ្រែអន្លង់វែងខ្ញុំហៅថាច្រក៨០៨មិញហ្នឹង ។

វណ្ណៈ	ចឹងខ្ញុំចង់ឲ្យពូនិយាយពីច្រក៨០៨ហ្នឹងនៅម៉្តុំណា?

សយៈ	ច្រក៨០៨នៅចន្លោះត្រពាំងតាវនិងអូរអង្រ្រែ ក្នុយដាក់ចឹងទៅច្រក៨០៨ហ្នឹងហើយ ។

វណ្ណៈ	នៅ៨០៨ហ្នឹងពីណាជាប្រធាននៅកន្លែងហ្នឹង?

សយៈ	៨០៨ហ្នឹងតាមមើលតាម៉ុក គាត់គ្រប់គ្រងដែលនៅម៉្តុំហ្នឹង ចុះមកលោក អី មុត នោះ ។

វណ្ណៈ	តាមុត?

សយៈ	បាទ!តាមុត ។

វណ្ណៈ	មាស មុត?

សយៈ	បាទ!តាមុត តាម៉ុក ហ្នឹងហើយនៅគ្រប់គ្រងហ្នឹង តាម៉ុក គាត់គ្រប់គ្រងទាំងអស់តំបន់គ្រប់កន្លែង ។

វណ្ណៈ	ចឹងដល់ពេលពូពិការ ពូចេញពី៨០១វិញចឹង?

សយៈ	អត់ទេ ខ្ញុំនៅ៨០១ដដែល ។

វណ្ណៈ	ចឹង៨០៨ពូនិយាយមិញ?

សយៈ	៨០៨ហ្នឹងជាប្រកទេ ប្រកដូចខ្ញុំថា១០០១មិញហ្នឹង តំបន់១០០១ ។

វណ្ណៈ	ចឹងជាឈ្មោះ ប្រក មិនមែនឈ្មោះកងពលទេ?

សយៈ	មិនមែនទេ បើទៅហ្នឹងវាមាន៩១២មាន៩៨០មាន៧៨៥ អាហ្នឹងនៅខាងអន្លង់វែង ។

វណ្ណៈ	ចឹង៩១២ហ្នឹងពីណាប្រធានកងពល?

សយៈ	ខ្ញុំអត់នេះដែលទេ តែ៩១២ហ្នឹងឈ្មោះ គង់ មេកាលហ្នឹង ។

វណ្ណៈ	ចឹង៩៨០?

សយៈ	ឈ្មោះ ទី ។

វណ្ណៈ	មានពីណាទៀត?

សយៈ	មាន៦១៦ តាញ៉ែន ៧៨៥ តាវឿន មានប៉ុន្មានទៀតខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ	កាលពូបានរៀបការឆ្នាំណាដែរ?

សយៈ	ខ្ញុំការឆ្នាំ១៩៧៩-៨០ហ្នឹងឯង ពេលឡើងមកភ្នំហើយបានការ ។

វណ្ណៈ	ចឹងពេលការហើយគ្រួសារគេឲ្យទៅសមរភូមិមុខដែលឬមួយនៅក្រោយ?

សយៈ	ខ្ញុំទៅមុខរហូតតែប្រពន្ធនៅក្រោយ បើមិនមានកូនចៅគេឲ្យដឹកជញ្ជូនដែរ ។

វណ្ណៈ	ចឹងបើសិនជាយើងមិនទាន់មានកូនគេឲ្យជួយដឹកជញ្ជូនដែរ?

សយៈ	បាទ ។

វណ្ណៈ	ចឹងពេលយើងមានកូនគេឲ្យនៅខាងក្រោយ?

សយៈ	បាទ!នៅខាងក្រោយជួយបិតចំរូងអីហ្នឹងយកមកដាក់ខាងព្រំដែនហ្នឹង ។

វណ្ណៈ	ចឹងនៅឆ្នាំ១៩៨៨ពូឈប់ទៅសមរភូមិមុខហើយ?

សយៈ	ឈប់ហើយខ្ញុំនៅគ្រប់គ្រងខាងក្រោយវិញ ។

វណ្ណៈ	ចឹងពូគ្រប់គ្រងប្រជាជន?

សយៈ បាទ! គ្រប់គ្រងប្រជាជនខាងក្រោយ ។

វណ្ណៈ ខាងក្រោយនៅម្តុំណា?

សយៈ ខាងក្រោយយើងចល័តមកដាំស្វាហ្នឹងខាងជុំបុរុនហ្នឹងដាំស្វា ។

វណ្ណៈ ប្រជាជនមានប៉ុន្មានដែរ?

សយៈ មួយអង្គភាព៨០១ហ្នឹងមានប្រហែលជា៥០០ទៅ៦០០គ្រួសារ ។

វណ្ណៈ ចឹងពូលែងបានកាន់អនុសេនាធំហើយមកគ្រប់គ្រងប្រជាជនវិញម្តង?

សយៈ បាទ ។

វណ្ណៈ ចឹងប្រជាជននៅខាងក្រោយមិនអាចទៅសមរភូមិមុខបាន នៅក្រោមតាម៉ុកទាំងអស់?

សយៈ បាទ ។

វណ្ណៈ ចឹងតាម៉ុក គាត់ឲ្យប្រជាជនទាំងអស់ហ្នឹងធ្វើការអីទៅ?

សយៈ កាលហ្នឹងបើថាទំនេរឲ្យបិតចំរូង ការផ្គត់ផ្គង់ជីវភាពគាត់ ។

វណ្ណៈ ចឹងពូធ្លាប់ឃើញគេបិតចំរូងហ្នឹងយ៉ាងម៉េច គេយកឫស្សីមកសម្រួចទៅ?

សយៈ បាទ! គេសម្រួច ។

វណ្ណៈ ប្រវែងវាប្រហែលជាប៉ុន្មានតឹកដែរ?

សយៈ ប្រហែលតាមវែងតាមខ្លី ប្រហែលជាបីតឹកអី ។

វណ្ណៈ ចឹងបីតឹកគេកប់ដីអីចឹងទៅ?

សយៈ ដោត សម្រួចលើសម្រួចក្រោម ។

វណ្ណៈ ចឹងចំរូងហ្នឹងគេថា សម្រួចហើយគេយកគ្រាំជ័រឆក់ឲ្យមានពីសហ្នឹងមានមែនដែលអត់?

សយៈ បើនៅខាងរតនគិរីច្បាស់ហើយ តែតំបន់យើងនេះមិនមានទេ កាលនោះ នៅខាងរតនគិរីឲ្យតែគាត់គ្រាំហើយឲ្យតែប៉ះទៅហើយ ជ័រឆក់ហ្នឹងនោះ ។

វណ្ណៈ ចឹងខាងជនជាតិបានមាន?

សយៈ បាទ! ខាងជនជាតិ ខ្មែរយើងរកមិនឃើញទេ អាហ្នឹង ។

វណ្ណៈ ចឹងកាលពូនៅខាង៨០៨ជាប្រជាជនចឹង តាម៉ុក គាត់ខបត្តម្ភឲ្យអត់មានខ្វះខាតទេ?

សយៈ បាទ! អត់មានខ្វះខាតទេ មានខ្វះខាតតែម្ហូបតែអង្ករមិនអីទេ ។

វណ្ណៈ ចឹងប្រជាជនបានហូបគ្រប់គ្រាន់ហើយមានសាលារៀនទេ មានឲ្យក្មេងៗបានរៀនទេ?

សយៈ កុនដែរ រឿងសាលារៀន ។

វណ្ណៈ ចឹងមានន័យថាអត់មាន?

សយៈ បាទ! ព្រោះកាលហ្នឹងយើងនៅក្នុងទឹកដីរបស់គេ ។

វណ្ណៈ៖ យើងរស់នៅជាំស្វាដុបរុនហ្នឹងជាទឹកដីយើងឬមួយទឹកដីថៃ?

សយៈ ទឹកដីថៃ ។

វណ្ណៈ៖ ចឹងទឹកដីថៃ?

សយៈ បាទ!ឧទាហរណ៍ថា យើងនៅ៨០៨ជាច្រកព្រំដែនហើយ១០០១ហ្នឹងក៏ច្រកព្រំដែនដែរ ថៃ- យើង៨០៨ក៏ថៃ- យើង ។

វណ្ណៈ៖ ចឹងជាំស្វាដុបរុនទឹកដីថៃតែជាប់ដីខ្មែរដែរ?

សយៈ បាទ!ជាប់ទឹកដីខ្មែរដែរ ។

វណ្ណៈ៖ ចឹងពូរស់នៅហ្នឹងដល់សភាពការណ៍ពេលក្រោយមកទៀតនេះ ដូចជាមានអ៊ុនតាក់ចូលមក ចឹង តើមានការប្រែប្រួលយ៉ាងម៉េចដែលនៅពេលហ្នឹង នៅតំបន់ខាងអន្លង់វែងអីហ្នឹងឆ្នាំ ១៩៩៣អីហ្នឹង តើការប្រែប្រួលខាងនយោបាយយ៉ាងម៉េចដែរ?

សយៈ អាហ្នឹងខ្ញុំក្តាប់មិនសូវបានដែរ តែដឹងថាពេលអ៊ុនតាក់ចុះមកហ្នឹង បើតាមមេដឹកនាំធំតែម្តង គាត់ឲ្យចុះចូលជាមួយរដ្ឋាភិបាលដើម្បីបង្កើតឲ្យមានគណៈបក្សហ្នឹងគេដើម្បីបោះឆ្នោត តែកាលនោះខ្ញុំវាមិនជ្រៅដែរ ក្រោយមកទៀតតាម៉ុក គាត់ប្រឆាំងរឿងហ្នឹងទៅ ចាប់បង្កបង្កើតវាយបន្តទៀតទៅ មិនមានការឯកភាពត្រូវធ្វើសង្គ្រាមបន្តទៀត ។

វណ្ណៈ៖ ចឹងដំបូងចង់រួមបោះឆ្នោតតែក្រោយមកមិនចូលវិញ?

សយៈ បាទ ។

វណ្ណៈ៖ ចឹងចេះតែមានសង្គ្រាមបន្តទៀត?

សយៈ មានបន្តទៀត ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូមានដឹងថា ផ្លូវធ្វើចុះមកអន្លង់វែងហ្នឹងមានដឹងថាតាម៉ុក គាត់ធ្វើពីឆ្នាំណាមកទេ ផ្លូវចុះមកពីលើភ្នំពីជាំមកមានដឹងទេ?

សយៈ កាលហ្នឹងខ្ញុំចាំមិនបានដែរ ដឹង តែកំណត់ថ្ងៃខែឆ្នាំរឿងកសាងហ្នឹងវាពិបាកដែរ ដូចជាឆ្នាំខ្ទង់ឆ្នាំ១៩៩៣ហ្នឹងហើយតាមមើល អាចមានកិច្ចព្រមព្រៀងហ្នឹងហើយបានធ្វើផ្លូវចុះមក ។

វណ្ណៈ៖ ចឹងនៅពេលគាត់ធ្វើផ្លូវចុះមក គាត់នាំប្រជាជនចុះមករស់នៅខាងក្រោមហ្នឹងតែម្តង?

សយៈ បាទ ។

វណ្ណៈ៖ ហើយមានបែងចែកទៅតាមភូមិផ្សេងៗ ទៅខ្លះនៅខាងត្រពាំងប្រាសាទខ្លះនៅអន្លង់វែងចឹងទៅ?

សយៈ បាទ ។

វណ្ណៈ ចឹងពេលចុះមកនៅខាងក្រោមនេះយើងក៏មិនបានសុខប៉ុន្មានដែរ ព្រោះកាលហ្នឹងមានខាងហ៊ុនស៊ីនប៉ិចសហការគ្នាវាយ ចឹងប្រជាជនហ្នឹងមានជួបគ្រោះថ្នាក់យ៉ាងម៉េចទៀតទៅ?

សយៈ ពេលកើតមានរឿងចឹងមកប្រជាពលរដ្ឋចេះតែមានការលំបាករបស់ប្រជាពលរដ្ឋចេះតែមានរហូតមក ព្រោះកាលឆ្នាំ៩៣យើងឯកភាពជាមួយខាងរដ្ឋាភិបាលដើម្បីបង្កើតគណៈបក្សចូលបោះឆ្នោត តែក្រោយមកតាម៉ុក គាត់មិនសុខចិត្តចេះតែមានសង្គ្រាមបន្តទៀតទៅខបស័គ្គហ្នឹងវាចេះតែមានហើយ ឧទាហរណ៍កន្លងមកចឹងមានវាយនៅទំនប់ដាច់ចឹង មានដុតផ្ទះដុតអីចឹង នៅអន្លង់វែងចឹងទៅមានវាយគ្នាក្តុងក្តាំងចឹងទៅ ឆេះនេះឆេះនោះចឹងទៅ ចឹងបានថា កាលលំបាកហ្នឹងវាចេះតែមានហើយមិនអត់ទេ ។

វណ្ណៈ ចឹងកាលហ្នឹងពូមានដឹងថា នៅកន្លែងស្រះឈូកហ្នឹងមានកន្លែងអាឈើអី កាលហ្នឹងប្រទេសចិនដ្តាច់ជំនួយហើយ តាម៉ុក គាត់បានកាត់ឈើមួយចំនួនលក់ឲ្យថៃ កាលហ្នឹងមានចឹងមែនដែលអត់?

សយៈ បាទ!ហ្នឹងជាការពិតហើយ នៅស្រះឈូកហ្នឹង ម៉ាស៊ីនអាឈើធំរបស់ថៃ ។

វណ្ណៈ ចឹងលក់ឈើដើម្បីយកលុយមកចិញ្ចឹមប្រជាជន?

សយៈ បាទ!ចិញ្ចឹមប្រជាជនចិញ្ចឹមកងទ័ពហ្នឹង ។

វណ្ណៈ ចឹងពេលក្រោយមកទៀតចេះតែមានបញ្ហាបន្តិចម្តងចេះតែកើតឡើងឈានដល់មានការហ៊ានសម្លាប់លោក សុន សេន អីហ្នឹងពូមានបានដឹងខ្លះទេ ពេលចាប់តាប៉ុល ពត យកទៅកាត់ទោសអីហ្នឹង ព្រោះសុទ្ធតែគ្នាឯងទាំងអស់?

សយៈ សើចខ្ញុំបានដឹងដែរ តែវាមិនសូវច្បាស់ ស្រពិចស្រពិលមានទំនាស់ទាស់ទែងគ្នាហ្នឹងមិនដឹងជាយ៉ាងម៉េចទេ បានជាកើតនៅជាចឹងវិញ ចឹងបានថារឿងរ៉ាវកន្លងមកហ្នឹងពូថា ដល់ត្រើតេមិនបានមកលេងគ្នាឯងចឹងវាយ៉ាប់អាចឹងណាស់ នាំយើងឲ្យឆ្លាតដូចជាល្ងង់ ។

វណ្ណៈ តែកាលដែលអ៊ំមកតស៊ូនៅតំបន់ហ្នឹង គឺពីដើមឡើយមានព្រៃឈើច្រើន មិនមែនស្រឡះដូចជាឥឡូវទេ?

សយៈ មានច្រើន ។

វណ្ណៈ ហើយសត្វព្រៃក៏មាន?

សយៈ សប្បុរណាស់ ពីដើមតាមហ្នឹងសុទ្ធតែអាចម៍ដំរី ។

វណ្ណៈ ចឹងដំរីទាំងអស់ហ្នឹងទៅណាអស់ទៅ?

សយៈ ទេ មិនដឹងជាទៅណាទៅណីអស់ទេ ។

វណ្ណៈ ចឹងចំណេញប្រទេសជិតខាងវិញ គេនៅសល់ព្រៃ?

សយៈ	បាទ!សរុបមកសង្គ្រាមបានធ្វើឲ្យហិនហោច ចឹងបានជាលោកគីម សាម៉េត គាត់និយាយថា តាមនយោបាយឈ្នះៗរបស់រដ្ឋាភិបាលហ្នឹង ដូចនេះធ្វើឲ្យមានការរីកចំរើន បើមានសង្គ្រាមទៀតវាហិនហោចរិចរិល ។

វណ្ណៈ	ចឹងបើយើងនៅតែបន្តវាយខ្មែររហូតមានកូនចៅណាកសាងប្រទេស?

សយៈ	បាទ ។

វណ្ណៈ	ចឹងបើមានសង្គ្រាមបន្តទៀតវាហិនមែនហ្នឹង បើសិនជាគ្មានការបញ្ចប់សង្គ្រាម អារឿងថាឲ្យចាញ់ឈ្នះហ្នឹងវាមិនងាយទេ ព្រោះចេះតែមានអ្នកជួយលុយកាក់បន្តៗចឹង មានដើមទុនវាយគ្នារហូតទៅ?

សយៈ	បាទ ។

វណ្ណៈ	កាលហ្នឹងវៀតណាមដកអស់មែន តែខ្មែរក្រហមវាយខ្លាំងគេមានមធ្យោបាយផ្សេងទៀត?

សយៈ	បាទ ។

វណ្ណៈ	តែបានចរចារគ្នាចឹងទៅខ្មែរបានសុខទាំងអស់គ្នាចឹងក៏វាស្រួលម្យ៉ាងដែរ?

សយៈ	បាទ ។

វណ្ណៈ	ទោះបីយើងរកបានតិចហូបតិចបានច្រើនហូបច្រើន តែយើងលែងភ័យរឿងសង្គ្រាម?

សយៈ	បាទ ។

វណ្ណៈ	យើងតែនាំគ្នាធ្វើការរកស៊ីទៅ ។

សយៈ	បាទ ។

វណ្ណៈ	ចឹងក្រោយមកទៀត ការដឹកនាំចរចារជាមួយរដ្ឋាភិបាលហ្នឹង តើជាគំនិតរបស់តាម៉ុកឬក៏ជាគំនិតរបស់មេកងពលមួយចំនួន បើតាមពូដឹង?

សយៈ	តាមមើលកិច្ចការផ្ទៃក្នុងរបស់តាម៉ុក ខ្ញុំមិនបានដឹងទេ បើថាសរុបមកដែលនាំឲ្យបានស្រុះស្រួលមូលមតិឯកភាពគ្នាមកដល់សព្វថ្ងៃហ្នឹង មួយមានចលនាមួយពីត្រពាំងប្រាសាទនេះទៅព្រះវិហារ អ្នកដឹកនាំមានឯកឧត្តម ជា កែវ ខ្ញុំនិយាយឲ្យច្បាស់តែម្តង មានលោក ជុំ ជាតិ មានលោក វ៉ាយ ពីន មួយទៀត ហើយមានខ្ញុំនេះ រស់ សយ ដែលបានដឹកនាំចលនានេះចូលទៅខាងព្រះវិហារ ដល់ក្រោយមកក៏វិលត្រឡប់មកដើម្បីបញ្ចប់សង្គ្រាមដែលដឹកនាំដោយឯកឧត្តម ជា កែវ លោក ជុំ ជាតិ ហ្នឹង វ៉ាយ ពីន នេះ នាំកម្លាំងចុះមកវាយបកវិញដោយជាមួយកម្លាំងយើងនៅខាងក្នុងនេះណាស់ ។

វណ្ណៈ	វាយបកទៅខាងណា?

សយៈ	វាយបកទៅរកតាម៉ុក វិញ ។

វណ្ណៈ	ឆ្នាំណាវាយបកទៅតាម៉ុកវិញ?

សយៈ	ឆ្នាំ១៩៩៨-៩៩ហ្នឹង។

វណ្ណៈ	ចឹងដល់ឆ្នាំ៩៩យើងត្រូវគ្នាអស់?

សយៈ	បាទ!៩៨-៩៩បញ្ចប់ហ្នឹង។

វណ្ណៈ	ចឹងដល់ឆ្នាំ១៩៩៩មានសមាហរណ៍កម្ម?

សយៈ	បាទ!មានសមាហរណ៍កម្មហ្នឹងហើយ តាមខ្ញុំដឹងពីខែបីកាលហ្នឹងឆ្នាំ៩៨ពីខែ៣មកចាប់វាយបកវិញ ដឹកនាំកម្លាំងតស៊ូនេះចូលទៅព្រះវិហារ ឯកភាពជាមួយហ្នឹងគំណាងរាស្ត្រខាងរដ្ឋាភិបាលរួបរួមគ្នាទៅវាយ ទៅវាយនៅអន្លង់វែងហ្នឹងតែម្តង ខាងអន្លង់វែងខ្ញុំដឹកនាំចលនាតស៊ូខ្ញុំមិនបានដឹងទេ តាមដឹងអាចលោក យឹម ដាន់ណា អ្នកដឹកនាំហ្នឹង។

វណ្ណៈ	ចឹងមានខាងអន្លង់វែងដែរ?

សយៈ	បាទ!ពេលក្រោយខាងនេះ តាមដឹងថ្ងៃទីប៉ុន្មានទេ បែបថ្ងៃទី២៨ឬថ្ងៃ១៥ទេ ខាងអន្លង់វែងបំផុសមនុស្ស មាន យឹម ពឹម អីហ្នឹងឯង។

វណ្ណៈ	ចឹងខាងអន្លង់វែងមានចលនាក្រោយទេ?

សយៈ	ក្រោយខាងត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ។

វណ្ណៈ	ចឹងខាងត្រពាំងប្រាសាទមានការដឹកនាំមុន?

សយៈ	បាទ!ដឹកនាំមុន។

វណ្ណៈ	ចឹងកាលហ្នឹងគិតឃើញយ៉ាងម៉េចបាននាំគ្នាទាំងលោក កែវ លោក ជុំ ជាតិ លោក ពីន ហើយ ពូ ហ្នឹងនឹកឃើញយ៉ាងម៉េចបានដាដោះដៃពីតាម៉ុក ហ្នឹង មានគំនិតយ៉ាងម៉េច?

សយៈ	ហ្នឹងវាវែងបន្តិច កាលហ្នឹងមែនទែនទៅវាបែងជាពីរក្តួយ ខាងខ្ញុំនេះគេហៅថា កម្លាំងលោក ប៉ុល ពត និយាយឲ្យច្បាស់តែម្តង ហើយខាងអន្លង់វែងនេះគេតាម៉ុក ហើយហ្នឹងនោះ ចឹងគេមានកន្លែងមួយគេហៅកន្លែង១៩ ជាកន្លែងអប់រំមានឈ្មោះ១៩ ហើយគេយកពួកខ្ញុំហ្នឹងទៅដាក់កន្លែង១៩ហ្នឹង។

វណ្ណៈ	កាលហ្នឹងនៅ១៩ហ្នឹងមានពីណាគ្រប់គ្រង?

សយៈ	១៩ហ្នឹង ទី១គេហៅ ខឹម ង៉ុន នោះ ទី២ ស្អី ញ៉ន ទេ នៅគ្រប់គ្រងហ្នឹងយកពួកខាងខ្ញុំនេះទៅដាក់ហ្នឹង ដើម្បីអប់រំ។

វណ្ណៈ	ឆ្នាំណាឆ្នាំ៩៨ហ្នឹង?

សយៈ	ឆ្នាំ៩៨ហ្នឹង ឆ្នាំ៩៧-៩៨ហ្នឹងឆ្នាំ៩៧។

វណ្ណៈ	ចឹង៩៧ទេ?

សយៈ	បាទ!៩៧-៩៨ ដាក់ចឹងទៅ៩៧-៩៨ទៅ ចាំខ្ញុំរៀបរាប់ទៀត ធម្មតាវាមានបងមានប្អូន ចឹងក្មួយនៅហ្នឹងណាស់ ថាបើសិនជាមិនគេចទេ គឺយើងត្រូវតែស្លាប់ហើយ បើចឹងអ្នកទាំងប្អូនមានខ្ញុំហ្នឹងដែរ មានគំនិតមួយសុំគេ សុំ តាញ៉ន សុំតាឌុំន មកប្រូតស្បូវដើម្បីយកមកធ្វើផ្ទះនៅកន្លែងអប់រំ១៩ហ្នឹង ។

វណ្ណៈ	ចឹងមានន័យថា យើងជាប់ឃុំហើយយើងខិតខំរកល្បិច?

សយៈ	បាទ!រកល្បិច ។

វណ្ណៈ	ចឹងពូនិយាយបន្តទៀត?

សយៈ	ដល់សុំទៅគាត់ឯកភាពឲ្យអ្នកទាំងបីមកប្រូតស្បូវមកធ្វើផ្ទះនៅកន្លែងហ្នឹង ហើយខ្ញុំគេមិនឲ្យមកទេ ព្រោះខ្ញុំវាពូកែឡាំប៉ាហើយកាលហ្នឹងឆ្លងទន្លេអីចឹង ខ្ញុំស្រួលដោះ ដល់គាត់ចេញបានមួយយប់មកខ្ញុំក៏សុំគេមកមើលគ្រួសារឆ្លងទន្លេនេះ សុំបានហើយក៏មកជួបគ្នាបានរកពេលវេលាគឺថ្ងៃ២៥ត្រូវចេញដំណើរ ប៉ុនដោយខបស័គ្គមានគេតាមដាននៅកន្លែងហ្នឹងទៀត កន្លែងមូលដ្ឋាននៅយើងអូរស្វាយហ្នឹង គេតាមដានមិនសុខសាប់ផែនការថ្ងៃ២៥ហ្នឹងក៏រំសាយចោល ក៏ដាក់ថ្ងៃសៅរ៍ទី២២នាំគ្នារត់ទាំងយប់ហ្នឹង ចេញពីអូរស្វាយទៅមែនទែនព្រះវិហារគេដើរមួយយប់អីដល់ ខ្ញុំដើរទាល់តែដល់ថ្ងៃទី២៨បានទៅដល់ខេត្តព្រះវិហារបានដល់ស្រុកគូលែន ។

វណ្ណៈ	ពេលយើងដើរហ្នឹង យើងមានទំនុកចិត្តថា ពេលចូលទៅដល់ខាងរដ្ឋាភិបាលហ្នឹងទទួលយើងឬមួយយើងដើរប្រថុយ?

សយៈ	ការគ្មានប្រព័ន្ធទាក់ទងផង ងងឹតឈឹងតែម្តង តែយល់ថាទោះបីស្លាប់យ៉ាងម៉េចយើងខំទៅនិយាយជាមួយគេគ្រាន់បើជាងគេឃុំហើយ ក៏ទៅមានឃុំមានស្អីគេហើយដឹងស៊ុបហើយដឹងដំណឹងហើយគេយកឡានមកទទួលនៅគូលែនហ្នឹង ។

វណ្ណៈ	ចឹងទទួលហើយឲ្យពូនៅណាទៀត?

សយៈ	ទៅខេត្តទៅនៅខេត្តយកពីស្រុកគូលែនហ្នឹងទៅនៅខេត្ត ។

វណ្ណៈ	ចឹងកាលហ្នឹងប្រពន្ធកូននៅទីនេះគេអត់មានធ្វើបាបទេចឹង?

សយៈ	យកទៅទាំងអស់ទាំងប្រពន្ធកូន ខ្ញុំទៅទាំងក្មេងទាំងចាស់ទាំងទ័ពមានជាង៦០នាក់ ។

វណ្ណៈ	ពេលទៅដល់សៀមរាបពូទៅជួបពីណាគេ?

សយៈ	អត់ទេ ខ្ញុំទៅខាងខេត្តព្រះវិហារ ។

វណ្ណៈ	ចឹងចេញពីគូលែនទៅខេត្តព្រះវិហារវិញ?

សយៈ	បាទ ។

វណ្ណៈ	ចឹងបានទៅជួបពីណា?

សយៈ	ទៅជួបឯកឧត្តម ខូយ គឹមហួរ ជាអ្នកទទួល ឯកឧត្តមអភិបាលរង ខូយ គឹមហួរ ។

វណ្ណៈ	ចឹងពេលដែលគាត់ទទួលហើយគាត់នាំពាក្យទៅដល់ខាងរដ្ឋាភិបាលយ៉ាងម៉េច?

សយៈ	បាទ!គាត់ទទួលយើងរាកទាក់ចឹងទៅខ្ញុំមកបានមួយថ្ងៃពីរថ្ងៃបានយន្តហោះគេមកយកខាងខ្ញុំហ្នឹងបួននាក់ទៅភ្នំពេញ ។

វណ្ណៈ	ចឹងកាលហ្នឹងទៅតែបួននាក់ទេ?

សយៈ	បាទ!បួននាក់ ។

វណ្ណៈ	ចឹងយ៉ាងម៉េចទៀតពូ?

សយៈ	ដល់ទៅភ្នំពេញចឹងទៅ សំខាន់គេសាកសួរយើងមើលកាលហ្នឹងជួបលោក ជុំ ហាក់ ហើយលោកអីមួយទៀតទេ ឈ្មោះ រឿប អ្នកយកពត៌មានណាស់ ។

វណ្ណៈ	ខាងរដ្ឋាភិបាល?

សយៈ	បាទ!ខាងរដ្ឋាភិបាល ។

វណ្ណៈ	ចឹងកាលហ្នឹងទៅដល់ជួបលោក ជុំ ហាក់?

សយៈ	បាទ! ជុំ ហាក់ ហើយក្រោយមកលោក ម៉ុល រឿប ខ្ញុំមិនសូវស្គាល់ច្បាស់ដែរ ។

វណ្ណៈ	ចឹងយ៉ាងម៉េចទៀត?

សយៈ	គាត់អ្នកយកពត៌មានហ្នឹងទៅសាកសួរយើងតាមដំណើរហ្នឹងទៅ យើងរៀបរាប់តាមហេតុផលដែលយើងចេញទៅចឹងណាស់ ។

វណ្ណៈ	បាទ ។

សយៈ	ហើយបានគេសម្រាកបំប៉នសុខភាពរយៈពេល១០ថ្ងៃ នៅភ្នំពេញ១០ថ្ងៃ នៅផ្ទះសំណាក់ហេង ឡាយ បំប៉ននៅហ្នឹង ។

វណ្ណៈ	ហ្នឹងឆ្នាំ៩០ប៉ុន្មាន?

សយៈ	ឆ្នាំ៩៨ដូចខ្ញុំនិយាយមិញហ្នឹង បានខ្ញុំបញ្ជាក់ពីក្រោមមកដល់ខែបី៩៨ហ្នឹងចុះបកមកវាយវិញ នេះដូចខ្ញុំបញ្ជាក់ពីមុន ។

វណ្ណៈ	ចឹងចុះមកវាយជាមួយតាម៉ុកវិញ?

សយៈ	បាទ!វាយជាមួយតាម៉ុក មានកម្លាំងខ្មែរក្រហមយើងដែលចូលនេះនោះ ។

វណ្ណៈ	ចឹងពេលហ្នឹងកម្លាំងខាងតាម៉ុកចាញ់ឬមួយយ៉ាងម៉េច?

សយៈ	ចាញ់ បើមិនចាញ់យ៉ាងម៉េច បើខាង យឹម ផាន់ណា យឹម ពឹម ហ្នឹង បកវាយដែលហ្នឹងចូលទៅសៀមរាបហើយបកវាយដែរ ។

វណ្ណៈ ចឹងដល់ពេលហ្នឹងតាម៉ុក គាត់រត់ទៅខាងណាវិញទៅ?

សយៈ ថា ទៅនៅត្រង់ណាទេ ដល់ក្រោយមកគេទៅចាប់យកទៅភ្នំពេញទៅ ខ្ញុំមិនបានតាមដានដែរ ចឹងបានថា កិច្ចការផ្ទៃក្នុងខាងតាម៉ុក មិនបានដឹងទេ តែកន្ទុងមកវាចឹង ។

វណ្ណៈ ចឹងកាលហ្នឹងតាម៉ុក គេមកចាប់គាត់នៅអន្លង់វែងហ្នឹងឬគេមកហៅគាត់ឲ្យទៅសៀមរាប?

សយៈ ដូចថាគេមកចាប់ ដូចថានៅម្ដុប ជុបម្ដូនោះ ខ្ញុំក្ដាប់មិនបានដែរ ព្រោះខ្ញុំនៅខាងខេត្តព្រះវិហារនោះកាលហ្នឹង ។

វណ្ណៈ ពូនៅព្រះវិហារឆ្នាំណា?

សយៈ ខ្ញុំថ្ងៃ២៨ដល់ព្រះវិហារ ។

វណ្ណៈ ថ្ងៃ២៨ឆ្នាំណា?

សយៈ ថ្ងៃទី២៨ឆ្នាំ៩៨ហ្នឹង ។

វណ្ណៈ ចឹងមុនឆ្នាំ១៩៩៨ហ្នឹងពូមាននៅខេត្តព្រះវិហារដែលអត់ មានធ្លាប់នៅទេ?

សយៈ អត់ទេ នៅមូលដ្ឋានយើងនេះហ្នឹង ត្រពាំងប្រាសាទហ្នឹង ។

វណ្ណៈ ម៉េចបានពូឈរជើងនៅព្រះវិហារវិញ?

សយៈ ខ្ញុំចង់និយាយថា ខ្ញុំចូលទៅនេះហ្នឹងណាស់ ចូលទៅជាមួយឯកឧត្ដម ជា កែវ ជុំ ជាតិរ៉ាយ ពីន ចូលទៅខេត្តព្រះវិហារឆ្នាំ៩៨ថ្ងៃទី២៨ហ្នឹងដល់ហ្នឹង ។

វណ្ណៈ ចឹងទេ?

សយៈ បាទ ។

វណ្ណៈ ចឹងខ្ញុំចង់សួរភ្ជាប់ទៅខាងព្រះវិហារបន្តិច ក្រោយឆ្នាំ៧៩ហ្នឹង កាលលើកមុនពូថាចល័តទៅដល់ខេត្តកំពង់ធំ ខេត្តព្រះវិហារក៏ពូធ្លាប់ទៅដែរ?

សយៈ បាទ ។

វណ្ណៈ ចឹងខ្ញុំចង់ដឹងចំណុចមួយទៀត ដូចជាមិនច្បាស់លាស់សោះមកដល់រាល់ថ្ងៃនេះ ថាកន្លែងផ្ទះក្រហមហ្នឹង ពីមុនថាតាម៉ុក ធ្វើជាផ្ទះឈើ តែមានអ្នកខ្លះនិយាយចឹង តែមានអ្នកខ្លះនិយាយថា មិនមែនទេ កន្លែងហ្នឹងរបស់ថៃអ្នកធ្វើទេ ចឹងពូអាចដឹងបានទេ ថាពិតប្រាកដហ្នឹងខាងណាខាងថៃជាអ្នកសាងសង់ឬតាម៉ុក ជាអ្នកធ្វើ បើតាមពូដឹង?

សយៈ ផ្ទះក្រហមនៅខាងព្រះវិហារនោះខាងថៃទេ ជាអ្នកធ្វើ ។

វណ្ណៈ ចឹងពូទៅឆ្នាំ១៩៩៨ហ្នឹងឃើញជាផ្ទះថ្មរបស់ថៃ?

សយៈ បាទ! ថៃហើយអាខាងនោះអូរ ។

វណ្ណៈ ចឹងមិនមែនតាម៉ុកជាអ្នកធ្វើទេ?

សយៈ	តាម៉ុក ចង់និយាយថា ខាងបុសស្បូវទេ តាម៉ុក បានធ្វើផ្ទះថ្មនោះនៅខាងព្រំដែនបុសស្បូវនោះហ្នឹងជាផ្ទះថ្ម តាម៉ុក ហើយហ្នឹង។

វណ្ណៈ	ចឹងផ្ទះក្រហមរបស់ថៃទេ?

សយៈ	បាទ។

វណ្ណៈ	ចឹងបានជាយើងចង់បានឲ្យមានពត៌មានច្បាស់ ពីព្រោះថាវាជារឿងព្រំដែនមួយដែរ?

សយៈ	បាទ។

វណ្ណៈ	ចឹងបើសិនជាតាម៉ុក ធ្វើអាចថាដីយើងពីផ្ទះក្រហមមកដល់ប្រាសាទ ចឹងបើជារបស់ថៃចឹងយើងមិនដឹងថា យើងកំណត់ព្រំដែនបានត្រឹមណាទេ ទោះបីជាតុលាការនៅក្រុងឡាអេសម្រេចថា ប្រាសាទព្រះវិហារជារបស់ខ្មែរហើយដីជុំវិញប្រាសាទហ្នឹងជារបស់ខ្មែរ តែវានៅតែមានការស្រពិចស្រពិលហ្នឹង ព្រោះអីខាងភាគីថៃហ្នឹងក៏គេមិនទាន់ដកទ័ពចេញដែរ ចឹងខ្ញុំចង់ឲ្យពូប្រាប់ បើសិនជាពូដឹងថាឆ្នាំ១៩៩៨ហ្នឹង ពូទៅឃើញហ្នឹង កាលហ្នឹងកងទ័ពថៃមានឈរនៅលើព្រះវិហារយើងដែលអត់ ហើយបានឈរជើងនៅម្តុំណាខ្លះ ពូអាចដឹងបានទេ ឬមួយពូមិនបានដឹងទេ?

សយៈ	មិនសូវបានដឹងដែរ តែមកដល់បច្ចុប្បន្ននេះ កន្លងមកផ្ទះក្រហមខាងនោះប្រាសាទនៅចន្លោះអូរបេះ អូរមួយខ័ណ្ឌបេះហ្នឹងជារបស់ថៃហើយហ្នឹង។

វណ្ណៈ	ចឹងមានន័យថា ពីអូរទៅខាងផ្ទះក្រហមថៃ ពីអូរមកខាងជើងប្រាសាទយើង?

សយៈ	បាទ!អាអូរឡើងមកប្រាសាទយើងហើយ ទឹកដីយើងហើយហ្នឹងគ្មានអីកែក្រឡៃទេ។

វណ្ណៈ	ចឹងពីដើមមកអ្នកខ្លះនិយាយថា តាម៉ុក ធ្វើហើយផ្លូវដែលចុះមករាល់ថ្ងៃនេះមិនទាន់មានថ្នល់កៅស៊ូទេ ជាថ្មជាធម្មតា គេថាថ្នល់កៅស៊ូនេះមានពេលដែលថៃហ្នឹងបើកច្រកជាមួយខាងរដ្ឋាភិបាលដើម្បីយកលុយភ្ញៀវទេសចរណ៍មកមើលប្រាសាទហ្នឹងទេ បានជាថៃធ្វើផ្លូវចុះមកកន្លែងអូរហ្នឹងតែម្តង អាហ្នឹងឮថាគេធ្វើក្រោយ ចឹងបានថាចង់ស្វែងរកចំណុចហ្នឹងដែរដើម្បីឲ្យច្បាស់ តែពូមិនបានដឹងច្បាស់ក៏មិនអីដែរ ចាំមើលព្យាយាមរកកងទ័ពណាដែលបានឈរជើងនៅលើប្រាសាទព្រះវិហារតាំងពីសម័យខ្មែរក្រហមរហូតដល់ក្រោយ៧៩ចឹងមករហូតដល់សមាហរណ៍កម្មនេះ បើសិនជាមានពីណាឈរជើងនៅហ្នឹងខ្ញុំចង់ជួប ចឹងពូមានស្គាល់ទាហានឈរជើងនៅហ្នឹងទេ?

សយៈ	មានលោក វ៉ាន់កុសល្យ អីហ្នឹងធ្លាប់នៅហ្នឹងចាំជួបគាត់ទៅហ្នឹងគាត់ប្រចាំនៅហ្នឹងហើយជាមួយលោក អ៊ិន ហឿន អីហ្នឹង ច្បាស់តែម្តង។

វណ្ណៈ៖ ចឹងចលនាដែលផ្ទាកមកខាងរដ្ឋាភិបាលហ្នឹង ទី១យល់ឃើញថាយើងវាយខ្មែរជាមួយខ្មែរឬមួយគិតថាយើងធ្វើសង្គ្រាមគិតថាវាខ្សោះខ្យល់លែងចង់ទៅមុខទៀតហើយបានជាយើងបកចូលជាមួយរដ្ឋាភិបាលឬមួយយ៉ាងម៉េច?

សយៈ ខ្ញុំពិនិត្យឃើញថា ធ្វើយូរៗហើយវាវិចវាវិលទាំងសងខាងមិនថាតែពួកខ្ញុំអ្នកតស៊ូឬកម្លាំងខាងរដ្ឋាភិបាលទេ ចឹងបានថាយល់ដូចនេះហើយ ហើយមានខបស័គ្គមេដឹកនាំខាងតស៊ូនេះមានការបែកបាក់គ្នាផង ក៏សុខចិត្តទៅឯកភាពជាមួយរដ្ឋាភិបាលទៅ ដើម្បីដោះស្រាយបញ្ចប់សង្គ្រាម អានេះជាការយល់របស់ខ្ញុំណាស់ ហើយទាំងអស់គ្នាក៏ចឹងដែរ បើមិនយល់ចឹងមិនមែននាំគ្នាទៅទេ សុទ្ធតែមេកងពលទៅយល់ចឹង ទី២ទី៣ទៀតបើយើងនៅទៅក៏វាមានគ្រោះអាសន្នដែរ ដែលយើងជាកូនចៅគាត់តាំងពីណាពីណើមកស្រាប់តែមានទោសមានវិន័យដាក់កន្ទែងអប់រំអីចឹង នេះជាការយល់របស់ខ្ញុំ ។

វណ្ណៈ៖ ចឹងបើនៅខាងអន្លង់វែងវិញ រឿងសម្លាប់លោក សុន សេន និងក្រុមគ្រួសារហ្នឹង បើតាមអ្នកកាសែតបរទេសហ្នឹងបានសំភាសជាមួយលោក ប៉ុល ពត គឺគាត់បានបញ្ជាឲ្យទៅសម្លាប់មែន ប៉ុន្តែលោក ប៉ុល ពត មិនឲ្យសម្លាប់ទាំងពូជទេ ឲ្យសម្លាប់តែបុគ្គល សុន សេន ទេ?

សយៈ បាទ ។

វណ្ណៈ៖ បើតាមឯកសារគាត់ នៅក្នុងបទសំភាស?

សយៈ បាទ ។

វណ្ណៈ៖ ប៉ុន្តែអ្នកទៅធ្វើហ្នឹងវាជ្រុលទៅសម្លាប់ទាំងអស់ ហើយការសម្លាប់ទាំងអស់ហ្នឹងគេចោទទៅលើតា០៥តា០៦បានជាតាម៉ុកហ្នឹងចាប់ពួកហ្នឹងយកមកសម្លាប់ចោលវិញ ចឹងបានជាខ្ញុំចង់ដឹងថានៅខាងត្រពាំងប្រាសាទហ្នឹង គិតថាតា០៥តា០៦ទៅសម្លាប់មែនឬជាបុគ្គលផ្សេង?

សយៈ បើគាត់ខ្ញុំថាមិនទេ វាអាចជាអ្នកផ្សេងតាមមើល ។

វណ្ណៈ៖ ចឹង?

សយៈ បាទ!ឧទាហរណ៍ថាឲ្យធ្វើប៉ុននេះទៅធ្វើប៉ុណ្ណោះចឹងទៅ មិនមែនគាត់ផ្ទាល់ទេ ។

វណ្ណៈ៖ ចឹងឥឡូវយើងចូលមកដល់សម័យកាលមួយលែងមានសង្គ្រាមខ្មែរនិងខ្មែរហើយ?

សយៈ បាទ ។

វណ្ណៈ៖ យើងត្រូវគ្នាអស់ហើយ ចឹងខ្ញុំចង់សួរប្រៀបធៀបទៅ កាលជំនាន់សង្គ្រាមនិងបច្ចុប្បន្ននេះតើពូយល់ថា តើមួយណារស់នៅស្រួលជាងបើតាមពូគិត?

សយៈ	ការយល់របស់ថា   ការអត់មានសង្គ្រាមគឺជីវិតរបស់ប្រជាពលរដ្ឋហើយខ្លួនខ្ញុំផ្ទាល់គឺវាសុខសានរហូត  តែបើមានសង្គ្រាមគឺមិនកំណត់ពេលវេលាដែលត្រូវស្លាប់បាត់បង់ទេ  អត់មានកំណត់ទេ   ហើយបើមានឈឺជំងឺសង្កាត់អីវាជារឿងផ្សេងទៀត   ខ្ញុំកំណត់ចឹង   ដូចនេះពីសង្គ្រាមមកបញ្ចប់សង្គ្រាម  ខ្ញុំទទួលយកការចប់សង្គ្រាមនេះ ។

វណ្ណៈ:	ចឹងខ្ញុំចង់ដឹងរឿងសាសនាវិញ  កាលជំនាន់នោះមានទេ  ជំនាន់ខ្មែរក្រហម?

សយៈ	សើច...មិនមានទេ ។

វណ្ណៈ:	ចុះជីវភាពកាលនោះយ៉ាងម៉េចដែរ?

សយៈ	ជីវភាពវាមិនដល់ដាច់បាយដាច់ទឹកដូចកាលឃោសនាថា  ស៊ីស្លឹកតាមូង  ស្លឹកត្រសេកអីមិនមានទេ  បាទគឺពេញរបុងដែរ  ទី១  ការផលិតដោយខ្លួនឯងបង្កបង្កើនផល  ទី២  មានការឧបត្ថមពីតាម៉ុកមក ។

វណ្ណៈ:	ហ្នឹងនិយាយក្រោយឆ្នាំ១៩៧៩?

សយៈ	បាទ ។

វណ្ណៈ:	តែនៅក្នុងរបបបីឆ្នាំវិញ  ពូអាចដឹងថាជីវភាពកាលហ្នឹងយ៉ាងម៉េចដែរ?

សយៈ	ក្នុងរបបបីឆ្នាំហ្នឹងអាចវេទនាហើយហ្នឹង  ប្រាប់ថាវេទនាប៉ុណ្ណឹងបានហើយ ។

វណ្ណៈ:	ចឹងកាលហ្នឹងមិនមានសាសនាទេ?

សយៈ	បាទ ។

វណ្ណៈ:	ឥឡូវយើងមានវត្តមានសាសនាគ្រប់គ្រាន់    សាសនាអីក៏មានដែលឲ្យតែមានអ្នកស្ម័គ្រចិត្តចូលចឹង?

សយៈ	បាទ ។

វណ្ណៈ:	ចឹងរាល់ថ្ងៃហ្នឹងពូកាន់សាសនាអីដែរ?

សយៈ	ខ្ញុំសាសនាព្រះពុទ្ធ  ព្រោះបានបួសបានរៀនដែរ ។

វណ្ណៈ:	ពូយល់ឃើញយ៉ាងម៉េចដែលសាសនាព្រះពុទ្ធ  បានអប់រំយើងឲ្យប្រព្រឹត្តអ្វីខ្លះទៅ?

សយៈ	មែនទែននិយាយឲ្យខ្លីមកសាសនាព្រះពុទ្ធឲ្យយើងដើរផ្លូវល្អ  និយាយឲ្យខ្លី ។

វណ្ណៈ:	ចឹងកាលពីដើមមកពូធ្លាប់បួសរៀនដែរ?

សយៈ	បាទ!ខ្ញុំបួសនេនបានបីវស្សាដែរ ។

វណ្ណៈ:	ចឹងបួសរៀនបានបីវស្សាហើយយ៉ាងម៉េចបានសឹក?

សយៈ	សឹកហ្នឹងមកចូលចលនា ។

វណ្ណៈ:	ចឹងចំពោះអ្នកជិតខាងពូ  តើសព្វថ្ងៃហ្នឹងពូមានការរាប់អានយ៉ាងម៉េចខ្លះដែរ?

សយៈ៖ ខ្ញុំមិនមានទំលាប់អីសោះជាមួយអ្នកជិតខាង អ៊ីដែលមានបញ្ហាខ្ញុំអត់នេះទេ ខ្ញុំមិនឲ្យមានតែមួងអ្នកជិតខាង ។

វណ្ណៈ៖ ចឹងចំពោះអ្នកជិតខាងមានដំណោះស្រាយអាចនិយាយគ្នាបាន?

សយៈ៖ បាទ ។

វណ្ណៈ៖ ចឹងចំពោះអ្នកជិតខាងយើងអាចមានទំនាក់ទំនងល្អទេ?

សយៈ៖ ល្អ ។

វណ្ណៈ៖ ចឹងចំពោះកូនចៅវិញ មានទំនាក់ទំនងយ៉ាងម៉េចដែរ កូនចៅក្រុមគ្រួសារដែលមានទំនាស់ទាស់ទាញឬមួយយ៉ាងម៉េចសព្វថ្ងៃ?

សយៈ៖ សព្វថ្ងៃដូចជាមិនអីទេ ធម្មតាមួយឆ្លាយមានតក់មាននាឡ មានអាខិលមានអាខូចអីខ្លះដែរ តែមានការអប់រំតាមត្រដាក់ បើត្រដាក់មិនបានទេអាចដាក់ក្ដៅបន្តិចទៅរាល់ថ្ងៃហ្នឹង មានការលំបាកតែក្រោយមកក៏បានទទួលវិញ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរទាក់ទងនិងគំរោងយើងចង់ធ្វើស្រែចឹង តើពូមានពិភាក្សាជាមួយកូនប្រពន្ធថាឆ្នាំនេះយើងត្រូវធ្វើអី ឆ្នាំទៅមុខទៀតយើងត្រូវធ្វើអី តើមានទំលាប់ពិភាក្សាបែបហ្នឹងដែលអត់?

សយៈ៖ បាទ!មានទម្លាប់ពិភាក្សា ។

វណ្ណៈ៖ ចឹងពិភាក្សានៅពេលណាខ្លះ?

សយៈ៖ យើងធ្វើស្រូវធ្វើអីមិនកើតចឹង ដីហ្នឹងវាអាចមានលទ្ធភាពដាំដំឡូងវិញអី ខ្ញុំធ្វើខ្ញុំពិភាក្សាគ្នាពេលយើងសម្រាកក្រោយពីការងារ ពេលល្ងាច ពេលហូបបាយអីហ្នឹង ។

វណ្ណៈ៖ ចឹងពូមានពិភាក្សាញឹកញាប់ដែរ?

សយៈ៖ បាទ!ដំណោះស្រាយដើម្បីជីវភាពគ្រួសារហ្នឹង មែនទែនទៅសឹងថារាល់ថ្ងៃដែរ ដើម្បីរកប្រកចេញ ។

វណ្ណៈ៖ បាទ ។

សយៈ៖ យើងត្រូវដោះស្រាយយ៉ាងម៉េចអីយ៉ាងម៉េច ។

វណ្ណៈ៖ ចឹងជីវភាពប្រចាំថ្ងៃរបស់ពូមានការហូបចុកគ្រាប់គ្រាន់ដែលឬមួយយ៉ាងម៉េច?

សយៈ៖ បាទ ។

វណ្ណៈ៖ ចឹងអត់មានអីទេ?

សយៈ៖ បាទ!គ្រប់គ្រាន់ តែក៏មិនហូរហៀរមានអីនិងគេដែរ ម៉ាសមរម្យ ។

វណ្ណៈ៖ ចឹងនៅនេះមានវត្តមានអីដែរ?

សយៈ មាន ។

វណ្ណៈ ចឹងពូឥឡូវមានបានទៅលេងស្រុកកំណើតដែរ?

សយៈ ម្ដាយស្លាប់អស់ហើយ នៅតែបងប្អូន នៅជីដូនមួយអីមិនសូវបានទៅលេងដែរ ក្រោយពីបញ្ចប់ឆ្នាំ១៩៩៩ហ្នឹងបានទៅលេងស្រុកពីរដង ក្រោយមកទៀតលែងទៅអើតហើយ បានជាមិនបានទៅអើត ព្រោះអស់បងប្អូនអស់ម៉ែឪនៅហ្នឹងហើយ ។

វណ្ណៈ ចឹងនៅខាងស្រុកអន្លង់វែងយើងមិនទាន់មានគំរោងការងារធំៗដូចជារោងចក្រ ឧស្សាហ៍កម្ម គេចុះមកធ្វើអី ដើម្បីអភិវឌ្ឍន៍ភូមិស្រុកមិនទាន់កើតមានទេ?

សយៈ បាទ!មិនទាន់មានទេ ។

វណ្ណៈ ចឹងមិនទាន់មានទេ?

សយៈ បាទ ។

វណ្ណៈ ចឹងនៅខាងស្រុកត្រពាំងប្រាសាទហ្នឹង ប្រជាជនប្រកបមុខរបរអីជាសំខាន់?

សយៈ សំខាន់ដំណាំមានបីប្រភេទ ទី១ ស្រូវ ទី២ សណ្ដែក ទី៣ ដំឡូង តែដំណាំយុទ្ធសាស្ត្ររបស់សព្វថ្ងៃគឺដំណាំកៅស៊ូ ជាដំណាំយុទ្ធសាស្ត្រហ្នឹង តែកៅស៊ូមានដោយបុគ្គលទេ មិនមានច្រើនទេក្នុង១០០មានបីអីនោះរឿងកៅស៊ូអីហ្នឹង តែជាយុទ្ធសាស្ត្ររបស់គេមានបីចំណុចហ្នឹង មានស្រូវ សណ្ដែកនិងដំឡូង ពោតក៏គ្មានដែរ ។

វណ្ណៈ ចឹងផលដំណាំស្រូវ សណ្ដែក ពោត ដំឡូងអីហ្នឹង ពេលធ្វើបានហ្នឹងវាអាចមានតម្លៃទប់ទល់ពេលយើងចុះទៅធ្វើដែរឬមួយយើងធ្វើទៅវាមិនសូវចំនេញឬមួយយ៉ាងម៉េចដែរ?

សយៈ អាហ្នឹងទៅតាមដាក់ស្ដែង ប្រើទន់តិចទន់ច្រើនចឹងទៅអាហ្នឹងមួយ ហើយដាក់ស្ដែងរឿងផលដំណាំរបស់យើងវា ឧទាហរណ៍ឆ្នាំនេះវាប៉ះពាល់អីទឹកវាច្រើនពេកវាអាចរលួយម៉ើមអីដំឡូងណាស់ ។

វណ្ណៈ បាទ ។

សយៈ បើសណ្ដែកអីហ្នឹងដូចជាមិនអីទេ គេធ្វើទៅបានចំនេញរបស់គេដែរ វាមិនសូវអីប៉ុន្មានទេ ។

វណ្ណៈ ចឹងខ្ញុំដូចជាអស់អីសួរពូទៀតហើយ តើពូមានមតិយោបល់អីចង់បញ្ចេញបន្ថែមនូវអ្វីដែលខ្ញុំមិនទាន់បានសួរពូ មានទេ?

សយៈ ដូចជាមិនមានអីទេ មានតែជូនពរឲ្យក្មួយទទួលបានជោគជ័យក្នុងការយកពត៌មាន ដើម្បីសម្រេចឲ្យបានជោគជ័យក្នុងការបំពេញការងារនេះ ខ្ញុំសូមជូនពរក្មួយគ្រប់កាលៈទេសៈដែលក្មួយចុះប្រតិបត្តិការនេះឲ្យទទួលបានជោគជ័យរគប់ភារកិច្ច ។

វណ្ណៈ   បាទ!ខ្ញុំសូមអរគុណពូច្រើនដែលបានសហការ ផ្តល់បទសំភាសន៍រឿងរ៉ាវដែលកើតមានឡើងកន្លងមក ដើម្បីទុកឲ្យកូនចៅជំនាន់ក្រោយបានដឹងបានឮជារឿងប្រវត្តិសាស្រ្តមួយដែលខ្មែរយើងធ្លាប់ឆ្លងកាត់កន្លងមក ចឹងខ្ញុំសូមអរគុណពូឲ្យពូមានសុខភាពល្អនិងអាយុវែងពូណាស់ ។

សយៈ   បាទ!អរគុណ ។

**ចប់**